(a) ថាប្រជាជនត្រូវបានធ្វើបំលាស់ទីដោយបង្ខំ ឬប្តូទីតាំងដោយផ្អែកលើការតម្រូវនៃការងារតាមរដូវកាល និងដើម្បី ឈានដល់ការសម្រេចការតស៊ូវណ្ណៈ។ សូមមើលកថាខណ្ឌ ២៧៨។

(b) ថាសហករណ៍ និងការដ្ឋានការងារ ត្រូវបានដំណើរការនៅទូទាំងប្រទេស ដើម្បីគ្រប់គ្រងប្រជាជន និង ធ្វើការត ស៊ូវណ្ណៈ។ សូមមើលកថាខណ្ឌ ២៧៩។

(c) ថា វិធីសាស្ត្រសមូហភាពរបស់បក្សកុម្មុយនិស្តកម្ពុជាមានបំណងធ្វើការតស៊ូវណ្ណៈ ក៏ត្រូវបានរួមបញ្ចូលទាំង បញ្ហាគ្រួសារ ដូចជាការរៀបអាពាហ៍ពិពាហ៍ផងដែរ។ សូមមើលកថាខណ្ឌ ២៧៩។

(d) ថាបក្សកុម្មុយនិស្តកម្ពុជាបង្កើតគោលនយោបាយដើម្បីកំណត់បទបញ្ជាកសាងគ្រួសារនិងអាពាហ៍ពិពាហ៍ ក្នុង គោលបំណងគ្រប់គ្រងប្រជាជន និងបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ២៧៩។

**មូលដ្ឋាន 41.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវិភាគរបស់ខ្លួនអំពី ជម្លោះ ប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និង វៀតណាម ដោយកាត់បន្ថយការយល់ដឹងអំពីលក្ខណៈនៃ អរិភាព និង ជាពិសេសការឈ្លានពានរបស់វៀតណាម។ សូមមើលកថាខណ្ឌ ២៨៨។

**មូលដ្ឋាន 42.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទង ទៅនឹងបរិបទអង្គហេតុនៃសំណុំរឿង ០០២/០២:

(a) ថា បក្សកុម្មុយនិស្តកម្ពុជា បានលុបបំបាត់ប្រព័ន្ធតុលាការ។ សូមមើលកថាខណ្ឌ ២៧៦, ៤១៧-១៨, ៣៩៤៤, ៤០០៨។

(b) ថាមានមន្ទីរសន្តិសុខយ៉ាងហោចណាស់ចំនួន ២០០ និង កន្លែងសម្លាប់នៅទូទាំងកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុង ពេលដែលពាក់ព័ន្ធ។ សូមមើលកថាខណ្ឌ ២៩៤, ៣៩៤០, ៣៩៥៤។

**មូលដ្ឋាន 43.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញ សម្រាប់គោលបំណងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបំពេញថា ការអនុវត្តនៃគោលនយោបាយបក្សកុម្មុយនិស្តកម្ពុជា ធ្វើការវាយប្រហារក្នុងលក្ខណៈទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលកម្ពុជាដោយមូលដ្ឋាននៃការរើសអើង។ សូមមើលកថាខណ្ឌ ៣១១, ៣១៣, ៣១៧, ៣១៩-២០។

**មូលដ្ឋាន 44.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការបកស្រាយអំពី "ជនស៊ីវិល" ដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចខាងក្រោម៖

(a) ក្នុងការជៀសវាងទិដ្ឋភាពតម្រូវសម្រាប់"ជនស៊ីវិល"ថា ការព្រឹត្តិការណ៍ដែលរងការចោទប្រកាន់នៃសំណុំរឿងថាការវាយប្រហារមួយករណី ថាជាការវាយប្រហារទៅលើប្រជាពលរដ្ឋកម្ពុជាទាំងមូល អាស្រ័យហេតុនេះហើយបានកាត់បន្ថយនូវភាពពាក់ព័ន្ធនៃអង្គហេតុ ដែលជនរងគ្រោះភាគច្រើនគឺជា សមាជិកនៃកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៣១១-១២។

(b) ក្នុងការរកឃើញថា ទាហានវៀតណាម ពុំបានចូលរួមដោយផ្ទាល់នៅក្នុងការប្រយុទ្ធគ្នាទាំងឡាយ ត្រូវទទួលបានការការពារខ្លួនដូចជាប្រជាជនស៊ីវិល។ សូមមើលកថាខណ្ឌ ៣១៨។

**មូលដ្ឋាន 45.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការអនុវត្តរបស់ខ្លួនចំពោះការការពារដែលបានផ្តល់ឱ្យបុគ្គលជាប់ពាក់ព័ន្ធនៅក្នុងការស៊ើបការ ដោយអនុលោមតាមអនុសញ្ញាទីបី ទីក្រុងហ្សឺណែវ និងពិធីសារបន្ថែម ទីមួយ។ សូមមើលកថាខណ្ឌ ៣៣៣-៣៤។

## V. ច្បាប់ជាធរមាន

### A. ច្បាប់ជាធរមាន នៃឧក្រិដ្ឋកម្ម

មូលដ្ឋាននៃបណ្តឹងសាទុក្ខដូចខាងក្រោមនេះ គឺជាកំហុសដែលធ្វើឱ្យមោឃដល់ការរកឃើញទាក់ទងនឹងច្បាប់ជាធរមានសម្រាប់ឧក្រិដ្ឋកម្មមួយចំនួន ដោយសាតតែការផ្តន្ទាទោសទាំងអស់នៅក្នុងសាលក្រមសម្រាប់ឧក្រិដ្ឋកម្មទាំងនោះ៖

**មូលដ្ឋាន 46.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការបកស្រាយរបស់ខ្លួនក្នុងមាត្រា ៨(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ទាក់ទងនឹងការងារដោយបង្ខំ។ សូមមើលកថាខណ្ឌ ៦៦៩។

**មូលដ្ឋាន 47.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការនិរទេស ការព្រមព្រៀងរវាងរដ្ឋអំណាច ដែលតំណាងឱ្យភាគីក្នុងការប្រព្រឹត្តជម្លោះប្រដាប់អាវុធ ដើម្បីដោះដូរក្រុមមនុស្ស ពីម្ខាងទៅម្ខាងនោះ ពុំបានធ្វើឱ្យប៉ះពាល់ដល់ភាពស្របច្បាប់នៃការផ្លាស់ប្តូរទីលំនៅឡើយ។ សូមមើលកថាខណ្ឌ ៦៨៥។

**មូលដ្ឋាន 48.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ពន្ធនាគារៈ

(a) ថា ការដកហូតសិទ្ធិសេរីភាពបុគ្គលដោយមិនមានការលើកលែង និង មិនមានយុត្តិកម្ម គឺជាការរំលោភបំពានប្រសិនបើអំពើនោះត្រូវបានធ្វើឡើងដោយពុំមានដំណើរការតាមផ្លូវច្បាប់ត្រឹមត្រូវ។ សូមមើលកថាខណ្ឌ ៦៩២-៩៣, ៦៩៨។

(b) ថាផ្នែកនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV គឺនាំឱ្យមានការវាយតម្លៃពីភាពស្របច្បាប់នៃការដកហូតសិទ្ធិសេរីភាព។ សូមមើលកថាខណ្ឌ ៦៩៤។

(c) ការបកស្រាយរបស់ខ្លួនពីលក្ខខណ្ឌត្រឹមត្រូវសម្រាប់រដ្ឋក្នុងការធ្វើបដិបញ្ញត្តិកាតព្វកិច្ចមួយចំនួន ដោយអនុលោមតាមមាត្រា ៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សូមមើលកថាខណ្ឌ ៦៩៦។

**មូលដ្ឋាន 49.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការរកឃើញថា អំពើខ្លះមានលក្ខណៈជាការធ្វើទារុណកម្ម រួមទាំងការវាយដំ។ សូមមើលកថាខណ្ឌ ៧០៤។

**មូលដ្ឋាន 50.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការរកឃើញថា ការប្រព្រឹត្តជាក់លាក់ជាមូលដ្ឋាននៃអំពើអមនុស្សធម៌ផ្សេងទៀត ពុំចាំបាច់ត្រូវបានកំណត់ថា ជាបទល្មើសជាក់លាក់ដែលត្រូវផ្តន្ទាទោសក្រោមច្បាប់អន្តរជាតិនោះឡើយ។ សូមមើលកថាខណ្ឌ ៧២៥។

**មូលដ្ឋាន 51.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងនិយមន័យរបស់ខ្លួននៃអំពើរំលោភ។ សូមមើលកថាខណ្ឌ ៧៣១។

**មូលដ្ឋាន 52.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការផ្អែកលើសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ក្នុងការវាយតម្លៃពីច្បាប់ និងធាតុផ្សំនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរវាងឆ្នាំ ១៩៧៥ និង១៩៧៩។ សូមមើលកថាខណ្ឌ ៧៤៤-៤៧។

## B. ច្បាប់ជាធរមានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល

មូលដ្ឋាននៃបណ្តឹងសាទុក្ខខាងក្រោមនេះគឺជាកំហុស ដែលធ្វើឲ្យមោឃដល់ការរកឃើញរបស់អង្គជំនុំជម្រះទាក់ទងនឹងច្បាប់ជាធរមានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល (គឺជាទំរង់នៃការទទួលខុសត្រូវ) ដោយសារតែរាល់ការផ្តន្ទាទោសទាំងអស់នៅក្នុងសាលក្រមនៅក្រោមទំរង់ផ្តន្ទាទោសពីការទទួលខុសត្រូវនៃការជួយ និង ការលើកទឹកចិត្ត និងការទទួលខុសត្រូវរបស់ថ្នាក់លើដែលពឹងផ្អែកទៅលើការរកឃើញនេះ

**មូលដ្ឋាន 53.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ក្នុងការរកឃើញដោយចាត់ទុកថា ទាក់ទងនឹងទំរង់ទទួលខុសត្រូវដោយផ្ទាល់នៃការជួយ និងញុះញង់ គឺអ្នកជួយជ្រុំជ្រែង និងអ្នកញុះញង់ ត្រូវដឹងពីចេតនាជាក់លាក់របស់ជនដៃដល់។ សូមមើល កថាខណ្ឌ ៣៧២២។

**មូលដ្ឋាន 54.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងទំរង់នៃការទទួលខុសត្រូវដោយផ្ទាល់ ឬដោយទំរង់ផ្សេងទៀតរបស់ថ្នាក់លើ:

(a) ថាការទទួលខុសត្រូវរបស់ថ្នាក់លើ អាចកើតមានឡើងនៅលើមូលដ្ឋាននៃទំនាក់ទំនងទាំងដោយផ្ទាល់ និងប្រយោលជាមួយនឹងថ្នាក់ក្រោម។ សូមមើលកថាខណ្ឌ ៣៧២៥។

(b) អ្វីដែលជាវិធានការចាំបាច់ និង សមហេតុផលដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌសម្រាប់គោលបំណងនៃការទទួលខុសរបស់ថ្នាក់លើ។ សូមមើលកថាខណ្ឌ ៣៧២៦។

## VI. សហឧក្រិដ្ឋកម្មរួម

## A. គោលបំណងរួម (រួមទាំងគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា)

មូលដ្ឋានខាងក្រោមនេះគឺជាកំហុស ដែលនឹងធ្វើឱ្យមោឃដល់ការរកឃើញរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងគោលបំណងរួម បែជាការផ្តន្ទាទោសទាំងអស់នៅក្នុងសាលក្រមផ្អែកលើការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម:

**មូលដ្ឋាន 55.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញថា ផ្នែកខ្លះនៃគោលបំណងរួម ដែលរួមបញ្ចូល មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនិស្តកម្ពុជា ដូចជា នួន ជា ត្រូវបានផ្លាស់ប្តូ

ប្រជាជនទាំងស្រុងឲ្យក្លាយទៅជាសង្គមខ្មែរតែមួយ ដែលមានតែវណ្ណៈកម្មករ-កសិករ។ សូមមើលកថាខណ្ឌ៣៧៤៣ និង៣៩១៨។

**មូលដ្ឋាន 56.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញថា ចេតនារបស់ នួន ជា និងសមាជិកដែលត្រូវបានចោទប្រកាន់ដទៃទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលរួមមានគោលនយោបាយក្នុងកសាង ការបង្កើត និង ដំណើរការសហករណ៍ និង ការដ្ឋានការងារ ដែលរួមបញ្ចូលនូវទង្វើដូចខាងក្រោម:

(a) ដាក់លក្ខខណ្ឌអាក្រក់ដោយចេតនា ទៅលើលក្ខខណ្ឌរស់នៅ និង ការងារ ដើម្បីគ្រប់គ្រងលើប្រជាពលរដ្ឋ។ សូមមើលកថាខណ្ឌ ៣៩២៦។

(b) ដោយចេតនារក្សាលក្ខខណ្ឌដ៏អាក្រក់ទៅលើលក្ខខណ្ឌរស់នៅ និង ការងារ ដោយមិនបានដោះស្រាយ បើទោះបីជាដឹងពីផលប៉ះពាល់អំពីលក្ខខណ្ឌក៏ដោយ។ សូមមើលកថាខណ្ឌ ៣៩១៣។

(c) ការផ្សាយតាមវិទ្យុអំពីការកាត់បន្ថយម៉ោងធ្វើការ តែបែរជាបញ្ជាឱ្យបង្កើនម៉ោធ្វើការ។ សូមមើលកថាខណ្ឌ ៣៩១០ ដល់១១។

(d) ការបោសសម្អាតជាប្រព័ន្ធទៅលើប្រជាជនថ្មី អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ជនក្បត់ ជនប្រឆាំងនឹងបដិវត្តន៍ និង ជនផ្តាច់ខ្លួនផ្សេងៗទៀត ដែលត្រូវបានគិតថា មិនអាចបំពេញគោលដៅបដិវត្តន៍សម្រាប់ការរើសអើងលើមូលដ្ឋាននយោបាយ។ សូមមើលកថាខណ្ឌ ៣៩២៤។

**មូលដ្ឋាន 57.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញចេតនារបស់ នួន ជា និងសមាជិកដទៃទៀតដែលចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដែលរួមមានគោលនយោបាយអប់រំឡើងវិញនូវ "ធាតុអាក្រក់" និងសម្លាប់ "ខ្មាំង" ដែលរួមបញ្ចូលនូវទង្វើដូចខាងក្រោម:

(a) ការកំណត់ "ខ្មាំង" ដោយផ្អែកលើអត្តសញ្ញាណជាជាងសកម្មភាព។ សូមមើលកថាខណ្ឌ ៣៧៥១-៥២, ៣៧៥៤, ៣៧៦២-៦៥, ៣៧៦៧, ៣៧៦៩, ៣៧៧២, ៣៧៧៤-៧៥, ៣៧៧៧-៧៩, ៣៧៨១, ៣៧៨៣-៩១, ៣៧៩៣, ៣៧៩៧-៨០០, ៣៨០៣-០៤, ៣៨០៦, ៣៨១២, ៣៨១៤, ៣៨១៧-១៨, ៣៨២១, ៣៨២៣-២៥, ៣៨២៨, ៣៨៣០, ៣៨៣២, ៣៨៣៩។

(b) ខ្មាំងរបស់ បក្សកុម្មុយនិស្តកម្ពុជា ដែលរួមមាន CIA KGB និង ភ្នាក់ងារវៀតណាម អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ក្រុមប្រឆាំងនឹងបដិវត្តន៍ ក្រុមផ្តាច់ខ្លួន និង ក្រុមក្បត់បដិវត្ត ក្រុមសក្តិភូមិ ជនជាតិវៀតណាម និង ក្រុមផ្សេងៗទៀត ដោយសារតែមូលហេតុនយោបាយ។ សូមមើលកថាខណ្ឌ ៣៩៨២។

(c) "កម្ទេច" និង "បោសសំអាត (ឲ្យស្អាត) "ដែលមានន័យថា "សម្លាប់" លុះត្រាតែបរិបទបង្ហាញដោយផ្ទុយ។ សូមមើលកថាខណ្ឌ ៣៨៥៨ ដល់ ៥៩។

(d) ចេញសេចក្តីណែនាំដោយបោកបញ្ឆោតរបស់ បក្សកុម្មុយនិស្តកម្ពុជា នៅខែ មិថុនា ឆ្នាំ ១៩៧៨ ដើម្បីលើកលែងទោសដល់អ្នកដែលធ្វើសកម្មភាពខ្មាំង ក៏ប៉ុន្តែនៅតែបន្តចាប់ខ្លួន "ខ្មាំង"។ សូមមើលកថាខណ្ឌ ៣៩៧១។

(e) ប្រើកុមារ និង សមាជិកគ្រួសារនៅក្នុងតួនាទីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងសកម្មភាពរបស់ខ្មាំង។ សូមមើលកថាខណ្ឌ ៣៨៦០។

**មូលដ្ឋាន 58.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា "សត្រូវពិតប្រាកដ ឬ ត្រូវបានគិតទុក" របស់បក្សកុម្មុយនិស្តកម្ពុជា គឺជាក្រុមនយោបាយដែលអាចដឹងបាន និងថា ភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និងភ្នាក់ងារវៀតណាម អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ពួកសក្តិភូមិ ជនជាតិវៀតណាម ជនជាតិចាម និងក្រុមផ្សេងទៀត ដែលអាចត្រូវបានចាត់ទុកជាក្រុមនយោបាយ។ សូមមើលកថាខណ្ឌ ១១៧៤, ១៤០៧, ១៤០៩, ១៦៨៧, ១៨២១, ២៦០០, ២៨៣៧-៣៨, ២៩៨២-៨៣, ២៩៩៥, ៣១៣៨-៣៩, ៣៣២៣, ៣៣២៩, ៣៩៨២។

**មូលដ្ឋាន 59.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញចេតនារបស់ នួន ជា និង សមាជិកដទៃទៀតដែលចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដែលរួមមានគោលនយោបាយដើម្បីកំណត់គោលដៅក្រុមជាក់លាក់ ដែលរួមបញ្ចូលនូវទង្វើដូចខាងក្រោម:

(a) ដាក់គោលដៅទៅលើជនជាតិចាមដោយសារតែអត្តសញ្ញាណនៃក្រុម ដែលជាផ្នែកមួយនៃគោលដៅសំខាន់របស់បក្សដើម្បីបង្កើតសង្គមខ្មែរដែលគ្មានសាសនា និង ជាសង្គមខ្មែរតែមួយ។ សូមមើលកថាខណ្ឌ ៣៩៩០, ៣៩៩៣-៩៤។

(b) គោលនយោបាយទូលំទូលាយនៃការកំណត់ទិសដៅលើជនជាតិវៀតណាម ដោយការប្រព្រឹត្តមិនល្អនៅកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៣៩៩៩។

(c) លុបបំបាត់ការប្រតិបត្តិព្រះពុទ្ធសាសនា និង ហាមឃាត់ព្រះពុទ្ធសាសនានៅទូទាំងកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤០១៥-១៧, ៤០២០។

(d) ផ្តោតលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ដោយប្រព្រឹត្តមិនល្អនៅទូទាំងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤០២៦-៤៩។

**មូលដ្ឋាន 60.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ចេតនាដែលចូលរួមដោយ នួន ជា និង សមាជិកក្នុងសហឧក្រិដ្ឋកម្មរួម ដើម្បីគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយថាជនជាតិវៀតណាមគឺជាសត្រូវចម្បង ដែលគោលនយោបាយនេះត្រូវបានបង្កើតឡើងដើម្បីការពារ។ សូមមើលកថាខណ្ឌ ៣៥៣៩-៦៣, ៤០៦៣។

**មូលដ្ឋាន 61.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឱ្យឃើញថា នួន ជា គឺជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម បានចូលរួមក្នុងគោលបំណងរួមមួយជាមួយមេដឹកនាំ បក្សកុម្មុយនិស្តកម្ពុជា ផ្សេងទៀត រហូតដល់ថ្ងៃចាប់ខ្លួន ឬ ធ្វើអត្តឃាត សោ ភឹម, រស់ ញឹម, វ៉ន វ៉េត និង ជូ ចេត។ សូមមើលកថាខណ្ឌ ៤០៦៩។

**មូលដ្ឋាន 62.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា សោ ភឹម មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ក៏ប៉ុន្តែមានសេចក្តីសន្និដ្ឋានផ្ទុយគ្នានៅក្នុងសាលក្រម។ សូមមើលកថាខណ្ឌ ៣៧៤០។

**មូលដ្ឋាន 63.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការឆ្លើយតបទៅនឹងការការពារក្តីរបស់មេធាវីការពារក្តី ទាក់ទងនឹងខ្លឹមសារត្រឹមត្រូវនៃគោលបំណងរួម ដែលមិនមែនជាលក្ខណៈព្រហ្មទណ្ឌ ដែលរួមមាន:

(a) ក្នុងការអនុវត្តដូចគ្នាទៅលើបទដ្ឋាន "ការវាយតម្លៃជារួម" របស់ខ្លួន ចំពោះការវាយតម្លៃរវាងសំណុំរឿងរបស់មេធាវីការពារក្តី និង សហព្រះរាជអាជ្ញាទាក់ទងទៅនឹងគោលបំណងរួម។ សូមមើលកថាខណ្ឌ ៣៨៧១, ៣៩៣៣, ៤០៤១, ៤០២៥។

(b) ខកខានក្នុងការពិចារណាឱ្យបានគ្រប់គ្រាន់ចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ទាក់ទងទៅនឹងគោលនយោបាយបង្កើត និង ដំណើរការនៃសហករណ៍ និង ការដ្ឋានការងារ និង ការប្រព្រឹត្តលើពុទ្ធសាសនិក និង អតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ៣៩២៩, ៤០១៤,៤០២៥។

(c) ការខកខានក្នុងការធ្វើឱ្យមានទម្ងន់គ្រប់គ្រាន់ចំពោះភ័ស្តុតាងពាក់ព័ន្ធ ដែលអាចបង្កើតជាមូលដ្ឋានត្រឹមត្រូវនៃគោលបំណងរួម។ សូមមើលកថាខណ្ឌ ៣៧២៧-៤០៧៤។

**មូលដ្ឋាន 64.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការពឹងផ្អែកទាំងស្រុង ឬ ក៏ដោយមានកំហុស ទៅលើភ័ស្តុតាងជាក់លាក់នៅក្នុងការវិភាគខ្លឹមសារនៃគោលបំណងរួម ដែលរួមមាន:

(a) ការបកស្រាយខុស ឬ ការដកស្រង់នូវសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា ដែលរួមបញ្ចូលទាំងភាសាដែលចោទប្រកាន់ ឬភាសាជនកុម្មុយនិស្តឱ្យឃ្លាតចេញពីបរិបទត្រឹមត្រូវ។ សូមមើលកថាខណ្ឌ ៣៧៤៧, ៣៨១៨, ៣៨២៩-៣០, ៣៨៤៧-៥៥។

(b) ការរកឃើញថា បើទោះបីជាមិនអាចត្រូវបានបង្កើតឡើងឱ្យហួសពីវិមតិសង្ស័យ ដែល នួន ជា ចូលរួមក្នុងដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅខេត្តបាត់ដំបង និងពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) នៅចុង

ខែ សីហា ឆ្នាំ ១៩៧៥ នោះ នួន ជា បានដឹងពីរបាយការណ៍ដែលកើតចេញពីដំណើរទស្សនកិច្ចនោះ ហើយបានចូលរួមនៅក្នុងការអភិវឌ្ឍផែនការ និងគោលនយោបាយ ដែលបានឆ្លុះបញ្ចាំងនៅទីនេះ។ សូមមើលកថាខណ្ឌ ៣៨៨៨។

(c) តម្រូវឱ្យមេធាវីការពារក្តីលើកឡើងឱ្យលើសពីវិមតិសង្ស័យក្នុងការយកឈ្នះលើសំណុំរឿងរបស់សហព្រះរាជអាជ្ញា។ សូមមើលកថាខណ្ឌ ៣៩៤១។

(d) ក្នុងការអនុវត្តន៍បទដ្ឋានពីរ ចំពោះការវាយតម្លៃភស្តុតាងដែលមេធាវីការពារក្តីយកមកសម្អាង។ សូមមើលកថាខណ្ឌ ៣៨៨៦, ៤០៣០-៣១, ៤០៣៥, ៤០៣៧, ៤០៤០។

(e) ពឹងផ្អែកលើឯកសារដែលមិនស្គាល់អ្នកនិពន្ធ ឬក៏ប្រភពមិនត្រូវបានផ្ទៀងផ្ទាត់ ថាបានពិពណ៌នាត្រឹមត្រូវអំពីគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ៣៧៤៦, ៣៧៥១, ៣៨៩១។

(f) ពឹងផ្អែកលើភស្តុតាងនៃព្រឹត្តិការណ៍ដែលមិនប្រាកដថាបានកើតឡើង។ សូមមើលកថាខណ្ឌ ៣៧៧៥។

(g) ពឹងផ្អែកយ៉ាងខ្លាំងលើភស្តុតាងនៃដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានស្បថ។ សូមមើលកថាខណ្ឌ ៣៧៣៩, ៣៩៤២-៤៣, ៤០៣៨។

(h) ពឹងផ្អែកយ៉ាងខ្លាំងលើភស្តុតាងរបស់ Philip Short និង Henri Locard។ សូមមើលកថាខណ្ឌ ៣៩៥៣, ៤០៤៥។

(i) ពឹងផ្អែកយ៉ាងខ្លាំងទៅលើការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងមន្ទីរសន្តិសុខនកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៣៩៥១។

**មូលដ្ឋាន 65.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការកឃើញថា ការប្រព្រឹត្តឧក្រិដ្ឋកម្មគឺស្ថិតនៅក្នុងគោលបំណងរួម អាស្រ័យហេតុនេះហើយគោលបំណងរួមគឺមានលក្ខណៈជាឧក្រិដ្ឋកម្ម។ សូមមើលកថាខណ្ឌ ៣៩១៩-២៨, ៣៩៧៣-៨៧, ៣៩៩១-៩៨, ៤០០១-១២, ៤០១៨-២២, ៤០៥០-៦១, ៤០៦៤-៦៧, ៤០៦៨។

**មូលដ្ឋាន 66.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ដោយខកខានក្នុងការភ្ជាប់ទំនាក់ទំនងរវាងការប្រព្រឹត្តឧក្រិដ្ឋកម្ម រំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវទៅនឹងគោលបំណងរួម។ សូមមើលកថាខណ្ឌ ៤០០៦-១១។

**មូលដ្ឋាន 67.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ការរកឃើញថា ដើម្បីបង្កើតការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមប្រភេទI វាគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថាឧក្រិដ្ឋកម្មដែលបានចោទប្រកាន់អាចបង្កើនគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ហើយត្រូវបានស្ថិតក្នុងគោលបំណងរួម។ សូមមើលកថាខណ្ឌ ៣៨៦៥, ៣៩២០, ៣៩២២-២៣, ៣៩២៥-២៧, ៣៩៧៦,

៣៩៧៨-៨១, ៣៩៨៣, ៣៩៨៥-៨៦, ៣៩៩៣-៩៧, ៤០០៣-០៥, ៤០០៧-១១, ៤០២១, ៤០៥៣, ៤០៥៦, ៤០៦០, ៤០៦៦។

## B. យុត្តិសាស្ត្រការពារក្តីសត្វក្រពើរបស់ នួន ជា

មូលដ្ឋានកំហុសខាងក្រោមនេះ ដែលនឹងនាំឱ្យមោឃដល់ការរកឃើញរបស់អង្គជំនុំជម្រះទៅលើការការពារក្តីសត្វក្រពើរបស់ នួន ជា ពាក់ព័ន្ធនឹង "គោលបំណងរួម" នៃគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ដោយសារតែរាល់ការផ្តន្ទាទោសទាំងអស់នៅក្នុងសាលក្រមដោយផ្អែកលើការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម។

**មូលដ្ឋាន 68.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនកោះហៅសាក្សីសំខាន់ៗ ដូចជា ហេង សំរិន, អ៊ុក ប៊ុនឈឿន និង ប៉ុល សារឿន ក៏ប៉ុន្តែបានសម្រេចទាក់ទងនឹងការការពាក្តីសត្វក្រពើរបស់ នួន ជា ថា មិនបានផ្អែកទៅលើភស្តុតាងរបស់សាក្សី ឬក៏ត្រូវបានផ្លាស់ប្តូរដោយសក្ខីកម្មរបស់សាក្សី។ ឧទាហរណ៍នៃការរកឃើញបែបនេះរួមមាន៖

(a) ក្នុងការរកឃើញថាពុំមានភ័ស្តុតាងគួរឱ្យជឿជាក់ ដែលផែនការរបស់ សោ ភឹម ធ្វើសង្គ្រាមប្រឆាំងនឹង ប៉ុល ពត រហូតដល់ សោ ភឹម បានសង្ស័យពីការប៉ុនប៉ងរបស់ ប៉ុល ពត ដកលោកចេញពីអំណាចនៅឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ២០៣៩-៥០។

(b) ក្នុងការរកឃើញថា ប៉ុល ពត គឺជាអ្នកដែលគេចាត់ទុកថា ក្បត់ទៅវិញ។ សូមមើលកថាខណ្ឌ ២៩២។

(c) ថាគ្មានឯកសារគាំទ្រណាមួយក្នុងសំណុំរឿង សម្រាប់ការលើកឡើងថា ភ្នាក់ងារវៀតណាមបានធ្វើការយ៉ាងសកម្មនៅភូមិភាគពាយ័ព្យ ឬ ថាពួកគេបានគាំទ្រ បក្សពលករឥណ្ឌូចិនដែលកំពុងបន្តនៅកម្ពុជា។ សូមមើលកថាខណ្ឌ ១៩៦៩។

**មូលដ្ឋាន 69.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និងបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការមិនកោះហៅសាក្សីដែលបានស្នើដោយមេធាវីការពារក្តី និង បដិសេធចោលនូវទិដ្ឋភាពការពារក្តីសត្វក្រពើរបស់ នួន ជា ដែលថា សាក្សីទាំងនេះអាចមានភស្តុតាងសំខាន់ៗ៖

(a) សាក្សីបីនាក់ដែលត្រូវបានសម្ភាសដោយផលិតករខ្សែភាពយន្តលោក Robert Lemkin និង ថេត សម្បត្តិ គឺ ចាន់សារុធ (W3 W1 និង W4)។ សូមមើលកថាខណ្ឌ ១៨៥០។

(b) អតីតសមាជិកនៃកងពល ៣១០ វុង វ៉េ, ចាច់ សៀក និង ខែម សំហួន។ សូមមើលកថាខណ្ឌ ១៩០៥-០៦; E443។

**មូលដ្ឋាន 70.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និងបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការមិនទទួលយកភស្តុតាងជាក់លាក់ ឬការស៊ើបអង្កេតដើម្បីទទួលយកភស្តុតាងដែលបានស្នើដោយមេធាវីការពារក្តី ក៏ប៉ុន្តែបានសម្រេចទាក់ទងនឹងការការពារក្តីសត្វក្រពើរបស់ នួន ជា ដែលនឹងអាចត្រូវបានផ្លាស់ប្តូរដោយភសត្ថុតាងនេះ ដែលក្នុងចំណោមនោះរួមមាន៖

(a) ប្រតិចារឹកនៃសាក្សីបីនាក់ដែលត្រូវបានសម្ភាសដោយផលិតករ ខ្សែភាពយន្ត Robert Lemkin និង ថេត សម្បត្តិ ដែលអាចផ្តល់ភស្តុតាងសំខាន់ៗទាក់ទងនឹងរដ្ឋប្រហារ គឺ ចាន់ សាវុធ (W3) W1 និង W4។ សូមមើលកថាខណ្ឌ ១៨៥០, ១៨៧១, ១៩៣៤, ១៩៤០, ១៩៤២, ១៩៥២-៥៣, ១៩៦០, ១៩៦៧, ១៩៦៩-៧១, ២០០៥, ២០១១, ២០១៥, E416/4។

(b) ភ័ស្តុតាងឯកសារពាក់ព័ន្ធនឹងការចូលរួមរបស់តំបន់ស្វយ័ត ១០៦ និង លេខាឈ្មោះ ប៉ា ផល ហៅ សុត នៅក្នុងផែនការ និង ការរៀបចំរដ្ឋប្រហារ និង នៅក្នុងការផ្ទុះគ្រាប់បែកនៅខេត្តសៀមរាបក្នុងខែ កុម្ភៈឆ្នាំ ១៩៧៦ ។ សូមមើលកថាខណ្ឌ ១៨៧៦, ១៨៨៥។

**មូលដ្ឋាន 71.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការដាក់បន្ទុកតួនាទីរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញភស្តុតាងមកលើមេធាវីការពារក្តី និង តម្រូវឲ្យមេធាវីការពារក្តីលើកឡើងឲ្យហួសពីវិមតិសង្ស័យ នៅក្នុងការសម្រេចមិនទទួលយកនូវអំណះអំណាងការការពារក្តីសត្វក្រពើរបស់ នួន ជា រួមមាន៖

(a) ថា សោ ភឹម មិនបានព្យាយាមធ្វើឃាត ប៉ុល ពត នៅភ្នំពេញ នៅឆ្នាំ ១៩៧៥។ សូមមើលកថាខណ្ឌ ១៨៧១។

(b) ថាការអះអាងថា ប៉ា ផល ហៅ សុត បានរៀបចំផែនការបះបោរនៅក្នុងតំបន់ស្វយ័ត ១០៦ គឺការស្មាន ហើយថាការផ្ទុះគ្រាប់បែក នៅខេត្តសៀមរាបមិនមែនជាផែនការមួយដើម្បីបះបោរប្រឆាំងនឹង ប៉ុល ពត ទេ។សូមមើលកថាខណ្ឌ ១៨៨៦-៨៧។

(c) ថាការបាញ់ និង ការផ្ទុះគ្រាប់បែកនៅសាលាវិចិត្រសិល្បៈ និង ព្រះបរមរាជវាំងមិនមែនជាផ្នែកមួយនៃការប៉ុនប៉ងធ្វើរដ្ឋប្រហារទេ។ សូមមើលកថាខណ្ឌ ១៨៩៦-៩៧។

(d) ការទុកអាវុធរបស់កងពល ៣១០ មិនបាននាំទៅដល់ការសន្និដ្ឋានថា មានផែនការដើម្បីផ្តួលរំលំ ប៉ុល ពត ទេ។ សូមមើលកថាខណ្ឌ ១៩១៥-១៦។

(e) ថាការស្តុកទុកអាវុធ និង សម្ភារៈផ្សេងៗទៀតនៅភូមិភាគពាយ័ព្យ ត្រូវបានធ្វើដោយគ្មានបំណងចង់បង្កើតការបះបោរនោះ វាជាការមិនគួរឱ្យកត់សម្គាល់ ឬភស្តុតាងមិនអាចជឿទុកចិត្តបានថា ពិតជាបានកើតឡើង។ សូមមើលកថាខណ្ឌ ១៩៤៦-៥៣។

(f) ថាវៀតណាមមិនត្រូវការជំនួយពី សោ ភឹម ដើម្បីចូលទឹកដីកម្ពុជាទេ។ សូមមើលកថាខណ្ឌ ២០១០។

**មូលដ្ឋាន 72.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការអនុវត្តន៍នូវស្តង់ដារពីរក្នុងកំណត់ ថា ភស្តុតាងសម្រាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីថា ស្បូវ ហ៊ីម ហៅ អឿន មានផែនការដឹកនាំកងពល ៣១០ នៅក្នុងរដ្ឋប្រហារនោះ គឺមានបញ្ហាលើភាពគួរឲ្យជឿជាក់បាន ដោយសារតែខ្វះខាតភាពច្បាស់លាស់, ការពិពណ៌នាមិនជាក់លាក់, ការនិយាយជាទូទៅ, ឬត្រូវបានផ្អែកលើការនិយាយតៗគ្នា និងមិនអាចធ្វើតេសបាន។ សូមមើលកថាខណ្ឌ ១៩២៨។

**មូលដ្ឋាន 73.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃទៅលើភាពគួរឲ្យជឿជាក់នៃសក្ខីកម្ម និង ភាពគួរឲ្យទុកចិត្តបាននៃសាក្សី ដែលសំខាន់សម្រាប់ការការពារក្តី"សត្វក្រពើ"របស់ នួន ជា៖

(a) សែម ហឿន។ សូមមើលកថាខណ្ឌ ១៩១២។

(b) សែម អំ ។ សូមមើលកថាខណ្ឌ ១០៨-០៩, ១៩១៦។

(c) ស្បួយ សៅ។ សូមមើលកថាខណ្ឌ ១០៨-០៩, ១៩១៩។

(d) ឡាត ស្បួយ។ សូមមើលកថាខណ្ឌ ១៩៦០។

**មូលដ្ឋាន 74.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ស្បូវ ហ៊ីម ហៅ អឿន ត្រូវបានជម្រុញឱ្យផ្តួលរំលំមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាព្រោះគាត់មិនយល់ស្របនឹងគោលនយោបាយ។ សូមមើលកថាខណ្ឌ ១៩៣១។

**មូលដ្ឋាន 75.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការទាក់ទងជាប់ជាមួយសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ធ្វើឲ្យ សោ ភឹម មានការលំបាកក្នុងការប្រឆាំងនឹងពួកគេ។ សូមមើលកថាខណ្ឌ ២០០៥។

**មូលដ្ឋាន 76.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា វស់ ញឹម បានបន្តការអនុវត្តយ៉ាងពេញទំហឹងនូវគោលនយោបាយរបស់មជ្ឈិមបក្សនៅពេញអំឡុងក្នុងពេលកាន់តំណែងជាលេខានៃភូមិភាគពាយ័ព្យ។ សូមមើលកថាខណ្ឌ ១៩៣៨, ១៩៦៧, ១៩៧២។

**មូលដ្ឋាន 77.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាការចូលរួមរបស់ សោ ភឹម នៅភូមិភាគបូព៌ាក្នុងការបោសសំអាតក្នុងឆ្នាំ ១៩៧៦ រួមទាំង សួស នៅ ហៅ ឈូក មានន័យថា គាត់ជាសមាជិកដែលគួរឱ្យទុកចិត្តរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅពេលនោះ។ សូមមើលកថាខណ្ឌ ២០១៣-១៥។

**មូលដ្ឋាន 78.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មិនមានភស្តុតាងគួរឱ្យទុកចិត្តដែលថា សោ ភឹម បានទាក់ទងជាមួយវៀតណាមដែលជាផ្នែកមួយនៃការការប៉ុនប៉ងដើម្បីផ្តួលរំលំ ប៉ុល ពត។ សូមមើលកថាខណ្ឌ ១៩៨៥-៩៣, ២០៦៣។

**មូលដ្ឋាន 79.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា សមាជិកគ្រួសាររបស់ សោ ភឹម រួមទាំងភរិយារបស់គាត់ យាយការ៉ូ ត្រូវបានសម្លាប់ដោយកងកម្លាំងស្មោះត្រង់នឹង ប៉ុល ពត។ សូមមើលកថាខណ្ឌ ២០៥៤។

**មូលដ្ឋាន 80.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពពាក់ព័ន្ធនៃសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងការគំរាមកំហែងដល់អធិបតេយ្យភាពកម្ពុជាដែលបង្កឡើងដោយវៀតណាម។ សូមមើលកថាខណ្ឌ ២០៦៥។

## VII. **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា**

មូលដ្ឋានកំហុសខាងក្រោមនេះ អាចនឹងធ្វើឱ្យមោឃការរកឃើញរបស់អង្គជំនុំជម្រះចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ដោយសារការផ្តន្ទាទោសទាំងអស់នៅក្នុងសាលក្រមដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ការជួយ និង ការជំរុញ ឬ ការទទួលខុសត្រូវរបស់ថ្នាក់លើ:

**មូលដ្ឋាន 81.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការដឹងឮរបស់ នួន ជា ចំពោះលទ្ធភាពដ៏សំខាន់នៃការប្រព្រឹត្តបទល្មើស:

(a) ថា តាមរយៈតួនាទីរួមនៅក្នុងបញ្ហាពាក់ព័ន្ធនឹងការឃោសនា នួន ជា ត្រូវតែបានដឹងថា ការផ្សព្វផ្សាយរបស់បក្សកុម្មុយនិស្តកម្ពុជាអំពីការប្រុងប្រយ័ត្ន និងកំហឹងប្រឆាំងនឹង "សត្រូវ" អាចនាំឱ្យមានអំពើហិង្សាមិនអាចជៀសផុតឡើយ។ សូមមើលកថាខណ្ឌ ៤០៨០។

(b) ថា ភាគច្រើននៃប្រជាជន ដែលស្ថិតនៅក្នុងឋានៈគ្រប់គ្រងបក្សកុម្មុយនិស្តកម្ពុជាទទួលបានការអប់រំតិចតួច គោរពវិន័យយ៉ាងតឹងរ៉ឹង បញ្ចុះបញ្ចូលមនោគមន៍វិជ្ជា និង បង្រៀន ដើម្បីបញ្ឆោតប្រជាជន និងឱ្យប្រជាជនធ្វើសកម្មភាពស្របតាមគោលការណ៍សម្ងាត់ ហើយថា នួន ជា ពុំអាចមិនអើពើនឹងការផ្តល់អំណាចទៅមនុស្សបែបនេះ អាចនាំឱ្យមានការអនុវត្តន៍ត្រឹមត្រូវតាមមាគ៌ាបក្ស ដោយពុំមានការវិនិច្ឆ័យដ៏ត្រឹមត្រូវនោះឡើយ។ សូមមើលកថាខណ្ឌ ៤០៨០។

(c) ថា ការរំពឹងទុក ដែលសមហេតុសមផលតែមួយគត់ពីការបង្កើតប្រព័ន្ធសហករណ៍ ការដ្ឋានការងារ បទបញ្ជារៀបអាពាហ៍ពិពាហ៍ និងមន្ទីរសន្តិសុខ នៅទូទាំងប្រទេស ក្រោមការឃោសនារបស់បក្សកុម្មុយនិស្តកម្ពុជាអំពីការប្រុងប្រយ័ត្ន និង កំហឹងប្រឆាំងនឹង "ខ្មាំង" គឺថាវាអាចនាំឱ្យមានការធ្វើបាប និងការស្លាប់ ហើយប្រព័ន្ធរបៀបនេះ អាចពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ សូមមើលកថាខណ្ឌ ៤០៨១។

**មូលដ្ឋាន 82.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការការរកឃើញខាងក្រោមទាក់ទងទៅនឹងការដឹងឮរបស់ នួន ជា អំពីការចូលរួមក្នុងឧក្រិដ្ឋកម្មដោយសារតែតួនាទីខ្ពស់របស់គាត់នៅក្នុង បកក:

(a) ថា នួន ជា មានភារកិច្ចទទួលខុសត្រូវគ្រប់សកម្មភាពទាំងអស់របស់បក្ស ដែលលើសពីតួនាទី និងការទទួលខុសត្រូវផ្លូវការរបស់គាត់ ដែលបក្សប្រគល់ឱ្យ។ សូមមើលកថាខណ្ឌ ៤០៨២។

(b) ថា ក្នុងនាមជាអនុលេខាបក្សកុម្មុយនិស្តកម្ពុជា និងជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ នួន ជា ទទួលពត៌មានជាពិសេស ដែលអាចឱ្យគាត់ទទួលដំណឹងពីបទឧក្រិដ្ឋ ដែលត្រូវចោទប្រកាន់នៅពេលនោះ។ សូមមើលកថាខណ្ឌ ៤០៨២។

**មូលដ្ឋាន 83.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការដឹងឮរបស់ នួន ជា នៃការចូលរួមក្នុងឧក្រិដ្ឋកម្មតាមរយៈការដឹងឮរបស់គាត់អំពីគោលនយោបាយ ដែលគោលបំណងរួមត្រូវបានអនុវត្ត:

(a) ថា នួនជា បានដឹងពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅក្នុងពេលបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។ សូមមើលកថាខណ្ឌ ៤០៨៥, ៤០៨៨។

(b) ក្នុងការរកឃើញថា នួន ជា បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង ទាក់ទងទៅនឹងគោលនយោបាយបង្កើតមន្ទីរសន្តិសុខ និង ទីតាំងសម្លាប់មនុស្ស។ សូមមើលកថាខណ្ឌ ៤០៩៤។

(c) ថា នួន ជា បានដឹងពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤០៩៧-៩៨, ៤១០០។

(d) ថា នួន ជា បានដឹងពីបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤១០៣។

(e) នួន ជា បានដឹងឮពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងព្រះពុទ្ធសាសនាក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤១០៤-០៥។

(f) ថា នួន ជា បានដឹងអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តចំពោះអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៤១០៩។

(g) ថា នួន ជា បានដឹងអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តដោយអនុលោមតាមគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ក្នុងការរៀបអាពាហ៍ពិពាហ៍ និង ការកសាងគ្រួសារ។ សូមមើលកថាខណ្ឌ ៤១១០។

**មូលដ្ឋាន 84.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា នួន ជា បានដឹងពីឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ សូមមើលកថាខណ្ឌ ៤១១២-១៥។

**មូលដ្ឋាន 85.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការអនុវត្តដោយផ្ទាល់ និង ការផ្សព្វផ្សាយពីគោលបំណងរួមរបស់ នួន ជា:

(a) ថា នួន ជា បាននិយាយអំពីការលុបបំបាត់ជនជាតិវៀតណាម នៅក្នុងវគ្គសិក្សាជាមួយកម្មាភិបាល បក្សកុម្មុយនិស្តកម្ពុជានៅទីក្រុងភ្នំពេញ។ សូមមើលកថាខណ្ឌ ៤១៣១។

(b) ថា ដោយសារតែតួនាទីខ្ពស់របស់ នួន ជា នៅក្នុងគណៈអចិន្ត្រៃយ៍ គាត់បានបញ្ជាឱ្យចាប់ខ្លួន ធ្វើទារុណកម្ម និង សម្លាប់ទាហានរាប់រយនាក់របស់កងពលមជ្ឈិម១៧០ ដែលបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ នៅឆ្នាំ១៩៧៦។ សូមមើលកថាខណ្ឌ ៤១៣៨។

**មូលដ្ឋាន 86.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា នួន ជា មានបំណងប្រព្រឹត្តបទឧក្រិដ្ឋនៅតាមសហករណ៍ និងការដ្ឋានការងារ។ សូមមើលកថាខណ្ឌ ៤១៤៧។

**មូលដ្ឋាន 87.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា នួនជា មានបំណងធ្វើបាប និង រើសអើង "ខ្មាំង" របស់ បក្សកុម្មុយនិស្តកម្ពុជា តាមរយៈឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដែលទាក់ទងនឹង ការ "បោសសម្អាត" និង នៅមន្ទីរសន្តិសុខ និង ទីតាំងសម្លាប់។ សូមមើលកថាខណ្ឌ ៤១៤៨-៥២។

**មូលដ្ឋាន 88.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា នួន ជា មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋដែលជាផ្នែកមួយនៃគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ដែលដាក់គោលដៅប្រព្រឹត្តមិនល្អទៅលើជនជាតិចាម។ សូមមើលកថាខណ្ឌ ៤១៥៤។

**មូលដ្ឋាន 89.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងចេតនារបស់ នួន ជា ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃគោលនយោបាយ ដើម្បីកំណត់គោលដៅប្រព្រឹត្តមិនល្អទៅលើជនជាតិវៀតណាមៈ

(a) ថា នួន ជា មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រឲ្យមានការស្អប់ជនជាតិវៀតណាម។ សូមមើលកថាខណ្ឌ ៤១៥៨។

(b) ថាពាក្យសម្តី និងសកម្មភាពរបស់ នួន ជា ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ បង្ហាញពីការប្រមាថជនជាតិវៀតណាម និងមានចេតនាដោយផ្ទាល់ក្នុងការសម្លាប់ជនជាតិវៀតណាមក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសកម្ពុជាចាប់ពីខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ សូមមើលកថាខណ្ឌ ៤១៦០-៦១។

**មូលដ្ឋាន 90.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា នួន ជា មានចេតនាចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលជាផ្នែកនៃគោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ក្នុងការដាក់គោលដៅដោយប្រព្រឹត្តមិនល្អទៅលើពុទ្ធសាសនិក។ សូមមើលកថាខណ្ឌ ៤១៦៤-៦៥។

**មូលដ្ឋាន 91.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា នួន ជា មានចេតនាចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ដើម្បីដាក់គោលដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ៤១៦៦-៦៩។

**មូលដ្ឋាន 92.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា នួន ជា មានចេតនាចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃគោលនយោបាយរៀបការនៅទូទាំងប្រទេសរបស់បក្សកុម្មុយនិស្តកម្ពុជា និងចូលរួមជាមួយសមាជិកសហឧក្រិដ្ឋកម្មផ្សេងទៀត តាមរយៈសហឧក្រិដ្ឋកម្មរួម នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការប្រព្រឹត្តដែលកំណត់ថា ជាការបង្ខំឱ្យរៀបការ និង ការរំលោភ នៅក្នុងបរិបទនៃការរៀបការដោយបង្ខំ។ សូមមើលកថាខណ្ឌ ៤១៧០-៧២។

**មូលដ្ឋាន 93.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ក្រោមទំរង់នៃការទទួលខុសត្រូវដោយផ្ទាល់ក្នុងការជួយ និង លើកទឹកចិត្ត:

(a) ថា នួន ជា ទទួលខុសត្រូវក្នុងការជួយ និង ជំរុញឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ដោយមានចេតនាដឹងជាមុនថានឹងកើតមានឡើងនៅមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខភ្នំក្រោល សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម និងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ៤១៨០-៨៦។

(b) ថា ការប្រព្រឹត្តរបស់ នួន ជា ធ្វើឱ្យលេចចេញនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើមនុស្សឃាត ដែលបានប្រព្រឹត្តឡើងដោយចេតនាដោយប្រយោល ដោយបានលើកទឹកចិត្តមន្ត្រីបក្សកុម្មុយនិស្តកម្ពុជាថ្នាក់ក្រោម ឱ្យបំពេញភារកិច្ចយ៉ាងក្លៀវក្លាក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ៤១៨១-៨៤។

(c) ថា នៅគ្រប់កាលៈទេសៈទាំងអស់ នួន ជា បានដឹង ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើមនុស្សឃាត ដែលបានប្រព្រឹត្តឡើងដោយចេតនា ហើយខ្លួនបានជួយសម្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ សូមមើលកថាខណ្ឌ ៤១៨៣។

**មូលដ្ឋាន 94.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ក្រោមទំរង់នៃការទទួលខុសត្រូវមិនផ្ទាល់ និង ទំរង់ផ្សេងទៀតនៃការទទួលខុសត្រូវរបស់ថ្នាក់លើៈ

(a) ថា នួន ជា មានទំនួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះបទចោទទាំងអស់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ សូមមើលកថាខណ្ឌ ៤១៨៧។

(b) ថា ទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម ប្រាកដជាមានរវាង នួន ជា និងលេខាភូមិភាគ និងមេបញ្ជាការយោធា និងតាមរយៈខ្សែសង្វាក់នៃការបញ្ជា ផ្នែករដ្ឋបាល និង យោធារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយថា នួន ជា មានទំនាក់ទំនងដោយប្រយោលជាមួយថ្នាក់ក្រោមទាំងអស់ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ សូមមើលកថាខណ្ឌ ៤១៨៧។

(c) ថាតាមរយៈលក្ខន្តិកៈបក្ស និងការទទួលខុសត្រូវ ដែលត្រូវបានប្រគល់ឱ្យ នួន ជា មានអំណាចជាក់ស្តែង និងតាមផ្លូវច្បាប់ក្នុងការដាក់វិន័យ ដល់សមាជិកថ្នាក់ក្រោមរបស់បក្សកុម្មុយនិស្តកម្ពុជា និង យោធា។ សូមមើលកថាខណ្ឌ ៤១៨៩។

(d) ថា នួន ជា បានដឹងថា ថ្នាក់ក្រោមរបស់ខ្លួន ទំនងជាបាន ឬបានប្រព្រឹត្តឧក្រិដ្ឋកម្ម ឬថា នួន ជា មានហេតុផលដឹងពីបញ្ហានេះ ក្នុងនាមខ្លួនជាអ្នកក្ដាប់ព័ត៌មានក្នុងដៃបានគ្រប់គ្រាន់ ដែលអាចសួររកហេតុផលបន្ថែមទៀត។ សូមមើលកថាខណ្ឌ ៤១៩០-៩៤។

(e) ថា នួន ជា មានលទ្ធភាពច្រើនក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម លើឧក្រិដ្ឋកម្មនានាដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តដោយអនុលោមតាមគោលនយោបាយបក្សកុម្មុយនិស្តកម្ពុជា និងថា នួនជា មិនត្រឹមតែបានខកខានក្នុងការធ្វើដូច្នេះទេ ប៉ុន្តែថែមទាំងប្រព្រឹត្តផ្នែកខ្លះនៃបទឧក្រិដ្ឋទាំងនោះតាមរយៈការបញ្ជា។ សូមមើលកថាខណ្ឌ ៤១៩៦-៩៧។

## ផ្នែក ៣. មូលដ្ឋានក្នុងការមោឃៈនៃការផ្ដន្ទាទោសបុគ្គល

## VIII. សហករណ៍ត្រាំកក់

មូលដ្ឋានខាងក្រោមនេះជាកំហុស ដែលនឹងធ្វើឱ្យមោឃរាល់ការផ្ដន្ទាទោសទាក់ទងនឹងសហករណ៍ត្រាំកក់ ប៉ុន្តែចំពោះបញ្ហាពាក់ព័ន្ធនឹងការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងវៀតណាមនឹងត្រូវបង្ហាញនៅក្នុងផ្នែកដាច់ដោយឡែក:

**មូលដ្ឋាន 95.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការអានដីកាដំណោះស្រាយទាំងមូលគឺគ្រប់គ្រាន់ដើម្បីផ្ដល់ការជូនដំណឹងអំពីការចោទប្រកាន់លើ នួន ជា ចំពោះសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ៨០៨, ១១៦២។

**មូលដ្ឋាន 96.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃអំពីការការពារក្ដីរបស់មេធាវីការពារក្ដី ទាក់ទងនឹងសហករណ៍ត្រាំកក់ដូចតទៅ:

(a) ខកខានក្នុងឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្ដីទាក់ទងនឹងកាលៈទេសៈដែលសហករណ៍ត្រាំកក់ត្រូវបានបង្កើតឡើង។ សូមមើលកថាខណ្ឌ ១១៥៥។

(b) ខកខានក្នុងការឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្ដីទាក់ទងនឹងការលំអៀងប្រឆាំងនឹងសង្គមនិយម។ សូមមើលកថាខណ្ឌ ១១៤៨-៤៩។

**មូលដ្ឋាន 97.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ហើយបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចទាក់ទងនឹង យថាភាព និង ភាពជឿជាក់នៃសំណុំឯកសារដែលត្រូវបានគេស្គាល់ថាជា "កំណត់ត្រាស្រុកត្រាំកក់":

(a) ថា ប្រភពនៃកំណត់ត្រាស្រុកត្រាំកក់ ដែលមានលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពីលេខ D០០១៦៧ ទៅ D ០០២៩៨ ត្រូវបានពន្យល់គ្រប់គ្រាន់តាមរយៈ Ben Kiernan ដែលបានបដិសេធមិនផ្តល់សក្ខីកម្មនៅ អវតក។ សូមមើលកថាខណ្ឌ ៨៣៦; E346/3។

(b) ថា យថាភាពនៃកំណត់ត្រាស្រុកត្រាំកក់ អាចត្រូវបានវាយតម្លៃតាមលក្ខណៈរួម។ សូមមើលកថាខណ្ឌ ៨៣៩។

(c) ថាកំណត់ត្រាស្រុកត្រាំកក់មានយថាភាព ទោះបីជាគ្មានការត្រួតពិនិត្យច្បាស់លាស់ក៏ដោយ ឬក៏មានសញ្ញាយ៉ាងអាចសម្គាល់បានលើឯកសារ។ សូមមើលកថាខណ្ឌ ៨៤០, ៨៧២, ៨៧៧-៧៨,៨៨៥។

**មូលដ្ឋាន 98.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ភស្តុតាងបានបញ្ជាក់ថា ការចូលរួមជាប់របស់ត តាម៉ុក នៅក្នុងព្រឹត្តិការណ៍នៅស្រុកត្រាំកក់នៅក្នុងពេលវេលាយ៉ាងច្រើនដែលមាននៅកនុងដីកាដំណោះស្រាយ។ សូមមើលកថាខណ្ឌ ៩០៥។

**មូលដ្ឋាន 99.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ជនភាសខ្លួនទៅស្រុកត្រាំកក់ត្រូវបានត្រួតពិនិត្យនៅវត្តចំប៉ា ហើយអ្នកខ្លះត្រូវបានសម្លាប់ ឬបាត់ខ្លួននៅបន្ទាប់ពីដំណើរការនេះ។ សូមមើលកថាខណ្ឌ ៩៦១-៦២, ៩៦៥។

**មូលដ្ឋាន 100.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញដូចខាងក្រោមទាក់ទងនឹង "ប្រភេទ" ប្រជាជននៅក្នុងសហករណ៍ត្រាំកក់:

(a) ថា បក្សកុម្មុយនិស្តកម្ពុជា បានកំណត់ប្រភេទមនុស្សនៅក្នុងសហករណ៍ត្រាំកក់ ហើយថានេះជាមូលដ្ឋានសម្រាប់ការវាយការណ៍ និង ត្រួតពិនិត្យសកម្មភាព និង អាកប្បកិរិយារបស់បុគ្គលម្នាក់ៗ។ សូមមើលកថាខណ្ឌ ៩៩៦។

(b) ថា គោលការណ៍ដំបូងរបស់ បក្សកុម្មុយនិស្តកម្ពុជា ក្នុងការកំណត់ប្រភេទប្រជាជន ប្រសិនបើធ្លាប់បានអនុវត្តនៅសហករណ៍ត្រាំកក់ នោះត្រូវបានលុបបំបាត់នៅពាក់កណ្តាលឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ១០០៧។

(c) ថា បក្សកុម្មុយនិស្តកម្ពុជា ផ្តល់របបអាហារខុសៗគ្នាសម្រាប់ប្រភេទមនុស្សផ្សេងគ្នាដោយផ្អែកលើប្រវត្តិរបស់ពួកគេ ហើយថា ក្រុមផ្សេងត្រូវបានផ្តល់អាហារតិចតួចជាង។ សូមមើលកថាខណ្ឌ ១០០៩, ១០១៦។

(d) ថា លក្ខខណ្ឌការងារដែលដាក់លើមនុស្សនៅសហករណ៍ត្រាំកក់ មានភាពខុសគ្នាទៅតាមប្រភេទប្រជាជន។ សូមមើលកថាខណ្ឌ ១០១៧។

(e) ថា អវត្តមានប្រជាជន១៧ មេសា ធ្វើការនៅមន្ទីរពេទ្យស្រុកត្រាំកក់ បានបញ្ជាក់ពីវិធីសាស្ត្រទូទៅ និង ផលវិបាកនៃការធ្វើចំណាត់ថ្នាក់ក្រុមប្រជាជននៅស្រុកត្រាំកក់។ សូមមើលកថាខណ្ឌ ១០៤២។

**មូលដ្ឋាន 101.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា ប្រជាជនថ្មីចាត់ទុកថាជាក្រុមនយោបាយសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ៨១៣, ១១៧៤, ១១៧៦-៧៩។

**មូលដ្ឋាន 102.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានកើតឡើងសហករណ៍ត្រាំកក់ប្រឆាំងទៅនឹងប្រជាជនថ្មី។ សូមមើលកថាខណ្ឌ ១១៧៣-៧៩។

**មូលដ្ឋាន 103.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញមួយចំនួនទាក់ទងនឹងជីវភាពរស់នៅ និង លក្ខខណ្ឌការងារនៅសហករណ៍ត្រាំកក់:

(a) ដែលលក្ខខណ្ឌការងារទូទៅនៅក្នុងសហករណ៍ត្រាំកក់ គឺជាមូលហេតុនាំឱ្យមានការស្លាប់ជាច្រើន។ សូមមើលកថាខណ្ឌ ១០២០។

(b) ថា ការរក្សានៅដដែលនូវលក្ខខណ្ឌរស់នៅ និង លក្ខខណ្ឌការងារនៅក្នុងស្រុកត្រាំកក់ បង្ហាញថា អាជ្ញាធរបក្សកុម្មុយនិស្តកម្ពុជាមានចេតនាដាក់លក្ខខណ្ឌបែបនេះទៅលើប្រជាជនរបស់ខ្លួនដោយដឹងថា នេះអាចនាំឱ្យមានការស្លាប់ ឬ ក្នុងការទទួលយកលទ្ធភាពនៃលទ្ធផលនេះ។ សូមមើលកថាខណ្ឌ ១១៤៥។

(c) បក្សកុម្មុយនិស្តកម្ពុជា មិនបានផ្តល់អាហារ ដែលជាមធ្យោបាយនៃការគ្រប់គ្រងប្រជាជន។ សូមមើលកថាខណ្ឌ ១០២៣។

(d) ថា ការលុបបំបាត់ទ្រព្យសម្បត្តិឯកជន គឺជាមធ្យោបាយគ្រប់គ្រងប្រជាជន។ សូមមើលកថាខណ្ឌ ១០២៤-២៥។

(e) ថា ការគំរាមកំហែងតិចតួចបំផុតទៅលើប្រព័ន្ធរបស់បក្សកុម្មុយនិស្តកម្ពុជា ត្រូវបានចាត់ទុកថាជាការក្បត់។ សូមមើលកថាខណ្ឌ ១០២៥។

(f) ថា ខ្លួនអាចពឹងផ្អែកទៅលើភស្តុតាងរបស់ រៀល សន ដែលទាក់ទងនឹងមូលហេតុនៃការស្លាប់របស់មនុស្សនៅមន្ទីរពេទ្យស្រុកត្រាំកក់។ សូមមើលកថាខណ្ឌ ១០៤៧។

**មូលដ្ឋាន 104.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការកំណត់ឡើងវិញនូវអង្គហេតុ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃឃាតកម្មតាមទំរង់ចេតនាដោយដឹងថា នឹងកើតមាន។ សូមមើលកថាខណ្ឌ ១១៣៩-៤៦។

**មូលដ្ឋាន 105.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុថា លក្ខខណ្ឌនៅក្នុងសហករណ៍ត្រាំកក់ចាត់ទុកជាការអនុវត្តន៍អំណាចទាំងអស់ ដែលជាសិទ្ធិជាម្ចាស់លើប្រជាជនរបស់ខ្លួន។ សូមមើលកថាខណ្ឌ ១១៥៤។

**មូលដ្ឋាន 106.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១១៥៤-៥៥។

**មូលដ្ឋាន 107.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិត្រូវបានកើតឡើងនៅក្នុងសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១១៩៥-៩៩។

**មូលដ្ឋាន 108.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញមួយចំនួនទាក់ទងនឹងការប្រព្រឹត្តដែលជាកំហុសដែលអាចដាក់ទោសបាននៅសហករណ៍ស្រុកត្រាំកក់:

(a) ថាបទល្មើសធ្ងន់ធ្ងរបំផុត រួមបញ្ចូលទាំងការប្រព្រឹត្តិគ្មានប្រយោជន៍និង / ឬការនិយាយដែលជាការវាយប្រហារបដិវត្ត និង ប្រព័ន្ធប្រមូលផ្តុំ។ សូមមើលកថាខណ្ឌ ១០៥៦-៦០។

(b) ថា ការលួចម្ហូបអាហារត្រូវបានចាត់ទុកថាជាបទល្មើសធ្ងន់ធ្ងរ ជាពិសេសបើប្រព្រឹត្តឡើងដោយប្រជាជនថ្មី។ សូមមើលកថាខណ្ឌ ១០៥៧។

**មូលដ្ឋាន 109.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញទាក់ទងនឹងការចាប់ខ្លួននៅសហករណ៍ត្រាំកក់:

(a) ថា ប្រជាជនថ្មីដែលប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជាត្រូវបានចាប់ខ្លួន។ សូមមើលកថាខណ្ឌ ១០៦៤។

(b) ភ័ស្តុតាងរបស់ ឯក ហឿន ពាក់ព័ន្ធនឹងបរិយាកាសភ័យខ្លាចនៅក្នុងសហករណ៍ត្រាំកក់ គឺគួរឱ្យជឿជាក់បាន។ សូមមើលកថាខណ្ឌ ១២០៤។

**មូលដ្ឋាន 110.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ថា ជាការបាត់ខ្លួនដោយបង្ខំត្រូវបានកើតឡើងនៅក្នុងសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១២០១-០៤។

## IX. ការដ្ឋានការងារទំនប់ត្រពាំងថ្ម

មូលដ្ឋានកំហុសខាងក្រោមដែលនាំឲ្យមោឃរាល់ការផ្តន្ទាទោសទាក់ទងនឹងការដ្ឋានការងារទំនប់ត្រពាំងថ្ម

**មូលដ្ឋាន 111.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការតម្រូវឱ្យមេធាវីការពារក្តីលើកឡើងលើសពីវិមតិសង្ស័យ ហើយបានអនុវត្តបទដ្ឋានពីរ នៅក្នុងការវាយតម្លៃភ័ស្តុតាងរបស់ខ្លួនពាក់ព័ន្ធនឹងមូលហេតុដែលនាំឱ្យចាប់ខ្លួន តាវ៉ាល់។ សូមមើលកថាខណ្ឌ ១២៣១។

**មូលដ្ឋាន 112.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការអនុវត្តបទដ្ឋានពីរចំពោះការវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បាន និង ភាពគួរឱ្យទុកចិត្តបានរបស់សាក្សីទាក់ទងនឹងការដ្ឋានទំនប់ត្រពាំងថ្ម ដោយយោងទៅលើភស្តុតាងដែលទាក់ទងនៅទីតាំងផ្សេងទៀត។ សូមមើលកថា ១២១០-១៤, ១៣៦៣-៦៦។

**មូលដ្ឋាន 113.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញចំពោះការដ្ឋានការងារនៅអាងត្រពាំងថ្ម ដោយយោងទៅលើភស្តុតាងទាក់ទងទៅនឹងទីតាំងផ្សេង។ សូមមើលកថាខណ្ឌ ១២៧៧, ១២៨៥។

**មូលដ្ឋាន 114.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញរបស់ខ្លួនដែលទាក់ទងទៅនឹងការយល់ដឹងរបស់អាជ្ញាធរ បក្សកុម្មុយនិស្តកម្ពុជា អំពីស្ថានភាពនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម:

(a) ក្នុងការរកឃើញថាមានទំនាក់ទំនងជាប្រព័ន្ធរវាងថ្នាក់មូលដ្ឋាន និងថ្នាក់ដឹកនាំជាន់ខ្ពស់ទាក់ទងនឹងលក្ខខណ្ឌការងារនិងការរស់នៅ។ សូមមើលកថាខណ្ឌ ១២៤៩-៥០។

(b) ក្នុងការរកឃើញថាមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជា បានដឹងឮអំពីលក្ខខណ្ឌនៅការដ្ឋានការងារទំនប់ត្រពាំងថ្មហើយមិនបានធ្វើអ្វីដើម្បីដោះស្រាយស្ថានភាពនោះទេ។ សូមមើលកថាខណ្ឌ ១២៥២-៥៣, ១២៨៧។

(c) ក្នុងការរកឃើញថា "មជ្ឈិមបក្ស" បានដឹងថាសេចក្ដីណែនាំរបស់ខ្លួនទាក់ទងនឹងម៉ោងធ្វើការ មិនត្រូវបានអនុវត្តតាមមូលដ្ឋានឡើយ។ សូមមើលកថាខណ្ឌ ១២៧៧។

(d) ក្នុងការរកឃើញថាអាជ្ញាធរ បក្សកុម្មុយនិស្តកម្ពុជា បានដាក់អោយកម្មករ នៅការដ្ឋានការងារទំនប់ត្រពាំងថ្មធ្វើការ នៅលក្ខខណ្ឌដែលបណ្ដាលឱ្យមានការឈឺចាប់ខាងផ្លូវចិត្ត ឬឈឺចាប់ ឬរបួសខាងរូបរាងកាយ ទោះបីជាដឹងអំពីផលប៉ះពាល់ក៏ដោយ។ សូមមើលកថាខណ្ឌ ១៤១៨។

**មូលដ្ឋាន 115.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញទាក់ទងនឹងលក្ខខណ្ឌការងារនៅការដ្ឋានការងារទំនប់ទឹកត្រពាំងថ្ម៖

(a) នៅក្នុងការរកឃើញថា បុគ្គលដែលពុំបានធ្វើការតាមការបែងចែក ត្រូវបានគេដាក់ទណ្ឌកម្មកាន់តែធ្ងន់ធ្ងរឡើង ហើយទីបំផុតបានបាត់ខ្លួន។ សូមមើលកថាខណ្ឌ ១២៩១-៩៤។

(b) ក្នុងការរកឃើញថា មានការងារពាក់ព័ន្ធនឹងគ្រោះថ្នាក់។ សូមមើលកថាខណ្ឌ ១២៧២។

**មូលដ្ឋាន 116.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃភ័ស្តុតាងរបស់ខ្លួនពាក់ព័ន្ធនឹងការសម្លាប់ដែលត្រូវបានចោទប្រកាន់នៅក្នុងការដ្ឋានការងារទំនប់ត្រពាំងថ្ម:

(a) ដោយដាក់ជាអប្បបរិមា និង អនុវត្តបទដ្ឋានពីរ ចំពោះការវាយតម្លៃរបស់ខ្លួនទៅលើសក្ខីភាពនៃភស្តុតាងដោះបន្ទុក។ សូមមើលកថាខណ្ឌ ១៣៧៣។

(b) ក្នុងការរកឃើញថាកម្មករនៅការដ្ឋានការងារទំនប់ត្រពាំងថ្មត្រូវបានសម្លាប់ក្រោយពេលចោទប្រកាន់ថា បានកុហករឿងកើតជំងឺខ្វាក់មាន់។ សូមមើលកថាខណ្ឌ ១៣៦៩, ១៣៧៩។

**មូលដ្ឋាន 117.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា អំពើមនុស្សឃាត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៣៧៨-៨០។

**មូលដ្ឋាន 118.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាប្រជាជនដួលនិងស្លាប់ជាញឹកញាប់ នៅក្នុងពេលធ្វើការនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៣៧៥។

**មូលដ្ឋាន 119.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការកំណត់ឡើងវិញនូវសកម្មភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ថាជាអំពើមនុស្សឃាតនៃឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ ក្នុងទម្រង់នៃចេតនាដឹងឮជាមុន នៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៣៨៤-៨៩។

**មូលដ្ឋាន 120.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថាការដាក់ឱ្យទៅជាទាសករនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៣៩៥-៤០២។

**មូលដ្ឋាន 121.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃរបស់ខ្លួនលើការរើសអើងចំពោះអ្នកធ្វើការនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម រួមមានដូចខាងក្រោម:

(a) ការខកខានក្នុងការកំណត់ក្រុមគោលដៅដោយហេតុផលនយោបាយ នៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៤០៩-១១។

(b) ក្នុងការរកឃើញថាប្រជាជនថ្មីគឺជាគោលដៅរើសអើង។ សូមមើលកថាខណ្ឌ ១៣៥៨។

**មូលដ្ឋាន 122.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៤០៩-១៣។

**មូលដ្ឋាន 123.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថាអំពើអមនុស្សធម៌ផ្សេងទៀតនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានប្រព្រឹត្តនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៤១៥-២១។

**មូលដ្ឋាន 124.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការបាត់ខ្លួនអ្នកធ្វើការនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម:

(a) ថាអ្នកធ្វើការ ដែលពុំបានបំពេញតាមការបែងចែក ត្រូវគេនាំយកទៅ និងបាត់ខ្លួន។ សូមមើលកថាខណ្ឌ ១២៩១-៩៤។

(b) ថា កម្មករដែលបានបាត់ខ្លួនពីការដ្ឋានការងារទំនប់ត្រពាំងថ្មត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ពួកគេដោយអាជ្ញាធរ។ សូមមើលកថាខណ្ឌ ១៤២៥។

**មូលដ្ឋាន 125.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថាអំពើអមនុស្សធម៌ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់មនុស្សត្រូវបានប្រព្រឹត្តនៅការដ្ឋានការងារទំនប់ត្រពាំងថ្ម។ សូមមើលកថាខណ្ឌ ១៤២៤-២៩។

## X. ការដ្ឋានការងារទំនប់ ១ មករា

មូលដ្ឋានខាងក្រោមនេះជាកំហុស ដែលនឹងធ្វើឱ្យមោឃភាពការផ្ដន្ទាទោសទាក់ទងនឹងការដ្ឋានការងារទំនប់ ១ មករា ប៉ុន្តែចំពោះការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ត្រូវបានបង្ហាញនៅក្នុងផ្នែកដាច់ដោយឡែក:

**មូលដ្ឋាន 126.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងវិសាលភាពនៃដីកាដំណោះស្រាយចំពោះការដ្ឋានការងារទំនប់ ១ មករា:

(a) ថាទំនប់ ៦ មករា និង ប្រព័ន្ធប្រឡាយ ១ និង ៦ មករា គឺជាផ្នែកមួយនៃសំណុំរឿង ០០២/០២។ សូមមើលកថាខណ្ឌ ១៤៣៤។

(b) ដែលថា វត្តបារាយជាន់ដែក គឺជាផ្នែកមួយនៃសំណុំរឿង ០០២/០២។ សូមមើលកថាខណ្ឌ ១៤៣៤។

**មូលដ្ឋាន 127.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ក្នុងការពឹងផ្អែកលើព្រឹត្តិការណ៍នៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយ ក្នុងការរកឃើញការប្រព្រឹត្តលើក្រុមខាងក្រោមនេះ នៅការដ្ឋានការងារទំនប់ ១ មករា:

(a) ប្រជាជនថ្មី។ សូមមើលកថាខណ្ឌ ១៦៤១-៥៣។

(b) ជនជាតិចាម។ សូមមើលកថាខណ្ឌ ១៦៥៥-៥៧។

**មូលដ្ឋាន 128.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការអនុវត្តបទដ្ឋានពីរ ចំពោះការវាយតម្លៃភាពជឿជាក់ និង ភាពគួរឲ្យជឿទុកចិត្តបានរបស់អតីតកម្មាភិបាល បក្សកុម្មុយនិស្តកម្ពុជា ដូចជា ស៊ូ សឿន, បាន សៀក, អៀង ឆាំ, កែ ពេជ្រវណ្ណៈ, ប៊ិច សុខា, យាន លន់, និង សូត្រ ទឿង។ សូមមើលកថាខណ្ឌ ១៤៣៩-៤១, ១៤៤៤, ១៤៦៤, ១៥១០, ១៥១៦, ១៥២៦, ១៥៤០, ១៥៤៦, ១៥៥០-៥១, ១៥៦៥-៦៦, ១៥៧០-៧១, ១៥៧៤, ១៥៧៩, ១៥៨៤, ១៥៨៨-៨៩, ១៦១៩-២០, ១៦៣២, ១៦៤៧, ១៦៥១។

**មូលដ្ឋាន 129.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ក្នុងការរកឃើញខាងក្រោមរបស់ខ្លួនទាក់ទងនឹងការប្រើប្រាស់ "ប្រវត្តិរូបរបស់ កែ ពក"៖

(a) ដោយពឹងផ្អែកលើ "ប្រវត្តិរូបរបស់ កែ ពក" បើទោះជាមានបញ្ហាយ៉ាងខ្លាំងទៅលើប្រភពដើម និង ភាពត្រឹមត្រូវរបស់វាក៏ដោយ។ សូមមើលកថាខណ្ឌ ១៤៤៣។

(b) ដោយពឹងផ្អែកលើ "ប្រវត្តិរូបរបស់ កែ ពក" សម្រាប់គោលបំណងផ្សេងក្រៅពីអ្វីដែលអង្គជំនុំជម្រះបានប្រកាស។ សូមមើលកថាខណ្ឌ ១៤៤៣, ១៤៨២, ១៥៨៦, ១៦៣១។

(c) ក្នុងការពិចារណាលើព្រឹត្តិការណ៍ដែលទាក់ទងទៅនឹង "ការបោសសំអាត" ផ្ទៃក្នុង បក្សកុម្មុយនិស្តកម្ពុជា ដែលទាក់ទងទៅនឹងរដ្ឋបាល និង ដំណើរការរបស់ការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៤៦១-៧០។

**មូលដ្ឋាន 130.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងឋានានុក្រមរដ្ឋបាលនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ថា ភូមិភាគកណ្ដាល (ឧត្តរចាស់) មិនអាចធ្វើអ្វីបានដោយគ្មានការសម្រេចពី "ថ្នាក់លើ"។ សូមមើលកថាខណ្ឌ ១៤៦៨, ១៤៧៤។

(b) ថា មជ្ឈឹមបក្សបានគ្រប់គ្រងលើភូមិភាគកណ្ដាល (ឧត្តរចាស់) និង ការដ្ឋានការងារទំនប់ ១ មករា បើទោះជាមានភស្តុតាងយ៉ាងច្បាស់លាស់អំពីការមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈឹមក៏ដោយ។ សូមមើលកថាខណ្ឌ ១៤៧០។

**មូលដ្ឋាន 131.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃទៅលើតួនាទីរបស់ នួន ជា នៅក្នុង "ការបោសសំអាត" នៅភូមិភាគកណ្ដាល (អតីតឧត្តរ) និងក្នុងការសាងសង់ទំនប់ ១ មករា:

(a) ថា នួន ជា រួមជាមួយអ្នកដទៃបានបញ្ជាឱ្យមាន "ការបោសសំអាត" ថ្នាក់ដឹកនាំនៅក្នុងភូមិភាគកណ្ដាល (ឧត្តរចាស់)។ សូមមើលកថាខណ្ឌ ១៤៦៦។

(b) ថា នួន ជា បានរៀបចំក្រុមការងារជាច្រើនដើម្បីបញ្ជូនទៅការដ្ឋានសាងសង់ទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៤៧៩-៨០។

(c) ក្នុងការខកខានមិនឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តីថា ការត្រួតពិនិត្យទូទៅសម្រាប់ការសាងសង់ទំនប់ ១ មករា គឺស្ថិតក្រោមអំណាចរបស់ក្រសួងការងារ ដែល នួន ជា មិនមែនជាអ្នកទទួលខុសត្រូវនោះទេ។ សូមមើលកថាខណ្ឌ ១៤៥៩-៦០។

**មូលដ្ឋាន 132.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការដឹងឮរបស់មេដឹកនាំអំពីលក្ខខណ្ឌនៅការដ្ឋានការងារទំនប់១ មករា:

(a) កែ ពក បានចូលរួមក្នុងប្រតិបត្តិការប្រចាំថ្ងៃ និង ការងាររដ្ឋបាលនៅការដ្ឋានការងារទំនប់ ១ មករា ហើយគាត់បានដឹងឮអំពីស្ថានភាពរស់នៅ និង លក្ខខណ្ឌការងារ។ សូមមើលកថាខណ្ឌ ១៤៨១-៨២, ១៥៨៦, ១៦៣១-៣២។

(b) ថា "មជ្ឈឹមបក្ស" ដែលរួមមាន នួន ជា បានដឹងឮអំពីស្ថានភាពការរស់នៅ និង លក្ខខណ្ឌការងារនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៤៨៦-៩៧, ១៦៣៣-៤០។

**មូលដ្ឋាន 133.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការចោទប្រកាន់អំពីការធ្វើការដោយបង្ខំនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ការគំរាមកំហែង និង ការដាក់ទណ្ឌកម្មត្រូវបានប្រើប្រាស់ដោយប្រធានកង ដើម្បីជំរុញឱ្យកម្មករធ្វើការតាមការកំណត់។ សូមមើលកថាខណ្ឌ ១៥៣២-៤១, ១៦១៦-២០, ១៦២៣។

(b) ថា ទាហាន និង យោធាមានវត្តមានដើម្បីតាមដានកម្មករ ដើម្បីតាមដានពួកគេធ្វើការឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ សូមមើលកថាខណ្ឌ ១៥៤២-៥១។

(c) ការទិតៀន និង ស្វ័យទិតៀន ត្រូវបានគេប្រើដើម្បីព្រមានដល់កម្មករអំពីផលលំបាកចំពោះការខកខានមិនបានបំពេញការងារ ដែលបានដាក់ជូន ហើយថា កម្មករ ត្រូវបានបាត់ខ្លួននៅបន្ទាប់ពីកិច្ចប្រជុំបែបនោះ។ សូមមើលកថាខណ្ឌ ១៥៥២, ១៥៦២, ១៧១១។

(d) ពលករមិនទទួលបានអត្ថប្រយោជន៍ពីពលកម្មរបស់ខ្លួន បើទោះជាមានការកើនឡើងនូវផលិតកម្មស្រូវដែលផលិតនៅទំនប់ ១ មករា ក៏ដោយ។ សូមមើលកថាខណ្ឌ ១៤៤៨, ១៤៥០, ១៤៥៤, ១៥៩៤-៩៥, ១៦៧៨, ១៦៨១។

(e) ថា ការងារនៅទំនប់ ១ មករា នៅតែត្រូវបានបន្តបង្ខំ ទោះបីជារដ្ឋស្ថិតក្នុងភាពអាសន្នក៏ដោយ។ សូមមើលកថាខណ្ឌ ១៦៧៧-៧៨។

**មូលដ្ឋាន 134.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការរឹតត្បិតលើបំលាស់ទីរបស់កម្មករនៅការដ្ឋានការងារទំនប់ ១ មករា គឺមិនចាំបាច់ ហួសប្រមាណ និង ខុសច្បាប់។ សូមមើលកថាខណ្ឌ ១៦២១-២៣, ១៦២៩។

**មូលដ្ឋាន 135.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា គ្រប់ទិដ្ឋភាពនៃជីវិតរបស់កម្មករនៅការដ្ឋានការងារទំនប់ ១ មករា ត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយបក្សកុម្មុយនិស្តកម្ពុជា រួមមានដូចជាទីជម្រក អាហារ និង ការថែទាំសុខភាព។ សូមមើលកថាខណ្ឌ ១៦៨០។

**មូលដ្ឋាន 136.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា សកម្មភាពរបស់អ្នកគ្រប់គ្រងកង ស្រុក តំបន់ និង ថ្នាក់ដឹកនាំភូមិភាគ ទំហំនៃការត្រួតពិនិត្យ និង រយៈពេលនៃការពន្យារបន្តនូវស្ថានភាពបែបនេះ បានបង្ហាញនូវចេតនា ដើម្បីប្រព្រឹត្តចំពោះអ្នកធ្វើការនៅការដ្ឋានការងារទំនប់ ១ មករា ដូចជាទំនិញ។ សូមមើលកថាខណ្ឌ ១៦៨៣។

**មូលដ្ឋាន 137.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៦៧៥-៨៤។

**មូលដ្ឋាន 138.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងស្ថានភាពស្បៀងអាហារដែលត្រូវបានចោទប្រកាន់នៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ថា បរិមាណអង្ករដ៏ច្រើនត្រូវបាននាំចេញ បើទោះបីជាមានការខ្វះស្បៀងអាហារនៅតាមមូលដ្ឋានក៏ដោយ។ សូមមើលកថាខណ្ឌ ១៤៥០, ១៤៥៤, ១៥៩៤-៩៥, ១៦៧៨, ១៦៨១។

(b) ថាកម្មករត្រូវបានហាមឃាត់ពីការស្វែងរកប្រភពអាហារបន្ថែម។ សូមមើលកថាខណ្ឌ ១៥៨៩, ១៥៩៥, ១៧០៣។

(c) ថា មានកង្វះស្បៀងអាហារដែលនាំឱ្យមានកង្វះអាហាររូបត្ថម្ភ ស្គមស្គាំង និង ការអត់ឃ្លាន។ សូមមើលកថាខណ្ឌ ១៥៨៦-៨៨, ១៧០៣។

**មូលដ្ឋាន 139.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញដូចខាងក្រោមរបស់ខ្លួនទាក់ទងនឹងការថែទាំសុខភាពសម្រាប់កម្មករនៅការដ្ឋានការងារទំនប់ ១ មករា:

(a) ពលករឈឺត្រូវបានបង្ខំឱ្យបន្តធ្វើការ។ សូមមើលកថាខណ្ឌ ១៦០៦, ១៦១០។

(b) ការថែទាំសុខភាពត្រឹមត្រូវមិនត្រូវបានផ្តល់ជូនដល់កម្មករទេ។ សូមមើលកថាខណ្ឌ ១៦០៧-១០។

(c) ពេទ្យ មិនមានបទពិសោធន៍ និង ខ្វះការបណ្តុះបណ្តាល។ សូមមើលកថាខណ្ឌ ១៦០៧, ១៦០៩-១០។

**មូលដ្ឋាន 140.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមរបស់ខ្លួនទាក់ទងទៅនឹងពេលវេលាធ្វើការនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ថា គោលនយោបាយរបស់ បក្សកុម្មុយនិស្តកម្ពុជា ដែលកំណត់ម៉ោងធ្វើការត្រូវបានគេគិតទុកនៅក្នុងករណីលើកលែង នៅក្នុងពាក្យសុំរបស់ខ្លួនទៅនឹង "ករណីពិសេស" រួមទាំង "សមរភូមិក្តៅ" ដូចជានៅទំនប់ ១ មករា ដែល

គោលនយោបាយនេះជាទូទៅមិនត្រូវបានយកចិត្តទុកដាក់។ សូមមើលកថាខណ្ឌ ១៥០៥, ១៥០៧, ១៥០៩, ១៧០៥។

(b) កម្មករដែលធ្វើការនៅការដ្ឋានការងារទំនប់ ១ មករា ត្រូវបានតម្រូវជាទៀងទាត់ឱ្យធ្វើការនៅពេលយប់។ សូមមើលកថាខណ្ឌ ១៥១០-១៩។

**មូលដ្ឋាន 141.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា គ្មានការអនុវត្តន៍ជាក់លាក់ ឬ ជាទូទៅនៃការផ្លាស់ប្តូរកម្មករនៅការដ្ឋានការងារទំនប់ ១ មករា ហើយបើទោះបីជាវិធានការបែបនេះត្រូវបានអនុវត្តន៍ ក៏មិនបានកាត់បន្ថយការលំបាកនៅក្នុងលក្ខខណ្ឌការងារសម្រាប់កម្មករជាច្រើនដែរ។ សូមមើលកថាខណ្ឌ ១៥២២-២៦។

**មូលដ្ឋាន 142.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា លក្ខខណ្ឌនៅការដ្ឋានការងារទំនប់ ១ មករា គឺជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់កម្មករ ដែលមានភាពស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត។ សូមមើលកថាខណ្ឌ ១៧០៣។

**មូលដ្ឋាន 143.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានចេតនាបង្កើតនូវស្ថានភាពរស់នៅ និង លក្ខខណ្ឌការងារមិនល្អទៅលើកម្មករនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៧០៦។

**មូលដ្ឋាន 144.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៦៩៨-៧០៧។

**មូលដ្ឋាន 145.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុនៅក្នុងការរកឃើញខាងក្រោមរបស់ខ្លួនទាក់ទងទៅនឹងការចោទប្រកាន់អំពីការប្រព្រឹត្តលើប្រជាជនថ្មីនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ថា ប្រជាជនថ្មីគឺជាក្រុមមួយត្រូវបានចាត់ទុកថា ជាខ្មាំងនៃបក្សកុម្មុយនិស្តកម្ពុជា ហើយថាផ្អែកលើស្ថានភាពនេះ ពួកគេត្រូវបានគេកំណត់គោលដៅសម្រាប់ការឃ្លាំមើល ការចាប់ខ្លួន ឬការសម្លាប់ជាដើម។ សូមមើលកថាខណ្ឌ ១៥៤២-៤៤, ១៦៤៦-៤៨, ១៦៨៧។

(b) ថាប្រជាជនថ្មី បានទទួលរងការរើសអើង។ សូមមើលកថាខណ្ឌ ១៦៥០-៥៣, ១៦៨៨-៨៩។

**មូលដ្ឋាន 146.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៦៨៦-៩២។

**មូលដ្ឋាន 147.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការចោទប្រកាន់អំពីការប្រព្រឹត្តលើជនជាតិចាមនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) ថា ចាមទទួលរងការរើសអើង។ សូមមើលកថាខណ្ឌ ១៦៥៦, ១៦៥៩។

(b) ថា ចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក។ សូមមើលកថាខណ្ឌ ១៦៥៦, ១៦៥៩។

**មូលដ្ឋាន 148.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការរឹតបន្តឹងដែលរងការចោទប្រកាន់ ដែលបានធ្វើទៅលើកម្មករចាមនៅការដ្ឋានការងារទំនប់១មករា ត្រូវបានធ្វើឡើងដោយចេតនា ក្នុងគោលបំណងរើសអើងប្រឆាំងនឹងពួកគាត់ ដោយសារតែសាសនា និង វប្បធម៌របស់គាត់។ សូមមើលកថាខណ្ឌ ១៦៩៥។

**មូលដ្ឋាន 149.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនសាសនាត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់ ១ មករា សម្រាប់ជនជាតិចាម។ សូមមើលកថាខណ្ឌ ១៦៩៤-៩៧។

**មូលដ្ឋាន 150.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការកំណត់អង្គហេតុ ដែលជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត នៅក្នុងទំរង់ចេតនាដោយដឹងឮថានឹងកើតមាន។ សូមមើលកថាខណ្ឌ ១៦៧២។

**មូលដ្ឋាន 151.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការស្លាប់នៅវត្តបារាយណ៍ជាន់ដែក:

(a) កម្មករទាំងនោះត្រូវបានបញ្ជូនពីការដ្ឋានការងារទំនប់១មករា ទៅវត្តបារាយណ៍ជាន់ដែក។ សូមមើលកថាខណ្ឌ ១៥៧២, ១៥៧៤, ១៥៨០។

(b) កម្មករដែលមកពីការដ្ឋានការងារទំនប់១មករា ត្រូវបានសម្លាប់នៅវត្តបារាយណ៍ជាន់ដែក។ សូមមើលកថាខណ្ឌ ១៥៧៦-៨០។

**មូលដ្ឋាន 152.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា កម្មករជាច្រើននាក់បានស្លាប់ដោយសារការងារ និង លក្ខខណ្ឌរស់នៅ នៅការដ្ឋានការងារទំនប់១ មករា។ សូមមើលកថាខណ្ឌ ១៦២៤, ១៦២៦-២៧, ១៦២៩, ១៦៧០។

**មូលដ្ឋាន 153.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាមេដឹកនាំ បក្សកុម្មុយនិស្តកម្ពុជា បានត្រៀមខ្លួនទទួលយកហានិភ័យ ដែលកម្មករនឹងស្លាប់ពីលក្ខខណ្ឌការងារ និងការរស់នៅ នៅការដ្ឋានការងារទំនប់១ មករា។ សូមមើលកថាខណ្ឌ ១៦៧១-៧២។

**មូលដ្ឋាន 154.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់១ មករា។ សូមមើលកថាខណ្ឌ ១៦៦៦-៧៣។

**មូលដ្ឋាន 155.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការបាត់ខ្លួនរបស់កម្មករនៅការដ្ឋានការងារទំនប់ ១ មករា៖

(a) អាជ្ញាធររបស់ បក្សកុម្មុយនិស្តកម្ពុជា បានផ្តល់ព័ត៌មានមិនពិតអំពីកន្លែងឃុំខ្លួនបុគ្គលដែលត្រូវបានចាប់ខ្លួន។ សូមមើលកថាខណ្ឌ១៥៦១, ១៥៦៥-៦៦, ១៧១០-១១។

(b) ថា កម្មករមួយចំនួនដែលបានបាត់ខ្លួនពីការដ្ឋានការងារទំនប់១មករា ត្រូវបានសម្លាប់ដោយពិតប្រាកដ។ សូមមើលកថាខណ្ឌ ១៥៦៥។

**មូលដ្ឋាន 156.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃទំរង់អមនុស្សធម៌ផ្សេងទៀតតាមរយៈការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំត្រូវបានកើតឡើងនៅការដ្ឋានការងារទំនប់១មករា។ សូមមើលកថាខណ្ឌ ១៧០៩-១២។

## XI. ការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង

មូលដ្ឋានកំហុសខាងក្រោមដែលនាំឲ្យមោឃភាពការផ្តន្ទាទោសទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង:

**មូលដ្ឋាន 157.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ក្នុងការសម្រេចទាក់ទងនឹងភាពគួរឱ្យទុកចិត្ត និង ភាពគួរឱ្យជឿជាក់បានរបស់បុគ្គលខាងក្រោមនេះ៖

(a) សែម ហឿន។ សូមមើលកថាខណ្ឌ ១៧៣២-៣៣, ១៧៣៩, ១៧៥៥-៥៨, ១៧៦៨-៦៩, ១៧៧៣, ១៧៧៦។

(b) ជុំ សាមឿន។ សូមមើលកថាខណ្ឌ ១៧១៩, ១៧៣១។

**មូលដ្ឋាន 158.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការសម្រេចទៅលើលក្ខខណ្ឌការងារនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ទាហានដែលត្រូវបានបញ្ជូនទៅធ្វើការ ត្រូវបានគេដកហូតតំណែង និង ត្រូវបានចាត់ទុកថា ជាកម្មករធម្មតា។ សូមមើលកថាខណ្ឌ ១៧៣៣។

(b) ទាហានដែលត្រូវបានបញ្ជូនឱ្យធ្វើការងារ គឺដើម្បីឱ្យ "កែខ្លួនឡើងវិញ" ឬ "លត់ដំ" ពីព្រោះពួកគេត្រូវបានកំណត់ថាជា "ខ្មាំង" ដោយសារតែជំនឿ ឬជំហរនយោបាយរបស់ពួកគេទៅលើបក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ១៧៣១-៣៥, ១៨២១។

**មូលដ្ឋាន 159.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញ លក្ខខណ្ឌដែលដាក់លើកម្មករនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ថាជាការប្រព្រឹត្តដ៏តឹងរ៉ឹងជាងការដាក់កម្រិតលើប្រជាជន។ សូមមើលកថាខណ្ឌ ១៨២២។

**មូលដ្ឋាន 160.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការសម្រេចទាក់ទងនឹងការបែងចែកការងារដោយរើសអើង នៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ទាហានដែលត្រូវបានគេចាត់ទុកថាជា "សមាសភាពមិនល្អ" ឬ "ខ្មាំង" ត្រូវបានទទួលរងនូវការប្រព្រឹត្តដ៏ឃោរឃៅជាងទាហាន និង កម្មាភិបាលដែលស្មោះត្រង់។ សូមមើលកថាខណ្ឌ ១៧៣១, ១៧៣៥, ១៧៤១-៤៣, ១៨២២-២៣។

(b) ថាមេធាវីការពារក្តីបកស្រាយខុសនូវភស្តុតាង ក្នុងការសរសេរសេចក្តីសន្និដ្ឋានរបស់ខ្លួនថា ពុំមានការរើសអើងនៃការងារ និងថា ទាហានកងពល ៣១០ ត្រូវបានគេ "ទុកចិត្ត" ស្រដៀងគ្នានឹងទាហានកងពល៥០២ ដែរ។ សូមមើលកថាខណ្ឌ ១៧៤១, ១៧៤៣។

**មូលដ្ឋាន 161.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ នៅក្នុងការផ្អែកដោយមិនត្រឹមត្រូវលើព្រឹត្តិការណ៍ដែលស្ថិតនៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយ ដើម្បីបង្កើតឱ្យមានការរកឃើញទាក់ទងនឹង

ចេតនាសម្លាប់ទាហានខាងភូមិភាគបូព៌ា នៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៧១៤, ១៧៨៣-៨៥, ១៨២៤។

**មូលដ្ឋាន 162.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានបង្កើតឡើងនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨១៩-២៨។

**មូលដ្ឋាន 163.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការកំណត់អង្គហេតុ ដែលជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើឃាតកម្មនៅក្នុងទំរង់ដែលមានចេតនាដឹងជាមួយថានឹងកើតមាន។ សូមមើលកថាខណ្ឌ ១៨០៥។

**មូលដ្ឋាន 164.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការសម្រេចទាក់ទងនឹងការស្លាប់ដោយសារតែលក្ខខណ្ឌការងារនៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ក្នុងការរកឃើញថា ទាហានជាច្រើនបានស្លាប់ដោយសារការបំបែកថ្ម ដោយសារតែបំណែកថ្មខ្ទាតមកត្រូវ និងវិធានការការពារមិនគ្រប់គ្រាន់ ដែលរួមបញ្ចូលទាំងការខ្វះឧបករណ៍ការពារ។ សូមមើលកថាខណ្ឌ ១៧៥៥, ១៨០០។

(b) បន្ថែមពីលើគ្រោះថ្នាក់ដោយការបំបែកថ្ម ក៏មានទាហានជាច្រើនបានរងរបួសឬស្លាប់ដោយសារតែគ្រោះថ្នាក់ផ្សេងទៀតដែរ។ សូមមើលកថាខណ្ឌ ១៧៥៧, ១៨០០។

(c) ថា ទាហានខ្លះបានស្លាប់ដោយសារតែការងារហួសកម្លាំង និង ការអត់ឃ្លាន។ សូមមើលកថាខណ្ឌ ១៧៥៨, ១៧៦០, ១៨០០។

**មូលដ្ឋាន 165.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការសម្រេចទាក់ទងនឹងការដឹងឮរបស់ បក្សកុម្មុយនិស្តកម្ពុជា នៃការស្លាប់នៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ថា គ្រោះថ្នាក់នៃការបំបែកថ្ម និង ការខ្វះឧបករណ៍ការពារមានន័យថាជីវិតរបស់អ្នកដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពបែបនេះត្រូវបានគេចាត់ទុកថាជារឿងតូចតាច។ សូមមើលកថាខណ្ឌ ១៧៤២, ១៧៥៦, ១៨០១។

(b) ថាទាក់ទងនឹងការងារហួសកំលាំង និង ភាពអត់ឃ្លាន អង្គាធរ បក្សកុម្មុយនិស្តកម្ពុជា បានផ្តល់ឱ្យទាហាននូវអាហារជាអប្បបរមាដែលចាំបាច់ដើម្បីរស់ ហើយត្រូវបានត្រៀមខ្លួន ដើម្បីទទួលយកហានិភ័យ ដែលទាហាននឹងស្លាប់ដើម្បីសម្រេចគោលដៅនៃការសាងសង់ព្រលានយន្តហោះ។ សូមមើលកថាខណ្ឌ ១៨០២។

(c) ថា ការរក្សាលក្ខខណ្ឌលំបាកក្នុងការរស់នៅ និង ការងារនៅការដ្ឋានការងារ ដោយរួមបញ្ចូលទាំងនៅបន្ទាប់ពីផលប៉ះពាល់ជាអវិជ្ជមានលើទាហាន បានបង្ហាញថា អជ្ញាធរមានចេតនាដាក់លក្ខខណ្ឌបែបនេះទៅលើប្រជាជនរបស់ខ្លួនដោយដឹងថា នេះអាចនាំឱ្យមានការស្លាប់ ឬ ក្នុងការទទួលយកលទ្ធភាពនៃលទ្ធផលនេះ។ សូមមើលកថាខណ្ឌ ១៨០៥។

**មូលដ្ឋាន 166.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានកើតឡើងនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨០០-០៦។

**មូលដ្ឋាន 167.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការចោទប្រកាន់លើការបង្ខំឱ្យធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង:

(a) ថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងការចោទប្រកាន់លើការបង្ខំឱ្យធ្វើការ គឺមិនពាក់ព័ន្ធ។ សូមមើលកថាខណ្ឌ ១៨១២។

(b) ថាពលកម្មត្រូវបានបង្ខំ បើទោះបីវាជា "ការងាររបស់យោធា"។ សូមមើលកថាខណ្ឌ ១៧៤៤, ១៨០៨-១២។

**មូលដ្ឋាន 168.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការរឹតត្បិតសិទ្ធិសេរីភាពក្នុងការធ្វើបំលាស់ទីដែលត្រូវចោទប្រកាន់នៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ថា ទាហានស្ថិតនៅក្រោមការឃ្លាំមើលរបស់ឆ្មាំ ឬ មេក្រុម។ សូមមើលកថាខណ្ឌ ១៧៦៨។

(b) ថា មានការរឹតបន្តឹងជាច្រើនទៅលើបំលាស់ទីរបស់ទាហាន។ សូមមើលកថាខណ្ឌ ១៧៦៩, ១៨១៤។

(c) ថា ការរឹតបន្តឹងការបំលាស់ទីរបស់ទាហាន ពុំមែនជាការចាំបាច់ ហួសកម្រិត និងខុសច្បាប់។ សូមមើលកថាខណ្ឌ ១៨១៤។

**មូលដ្ឋាន 169.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការដាក់លក្ខខណ្ឌនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ចាត់ទុកថា ជាការអនុវត្តសិទ្ធិអំណាចទាំងអស់នៃសិទ្ធិជាម្ចាស់គ្រប់គ្រងលើទាហាន។ សូមមើលកថាខណ្ឌ ១៨១៥។

**មូលដ្ឋាន 170.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មេដឹកនាំបានប្រើប្រាស់អំណាចដោយចេតនានៃសិទ្ធិអំណាច ដែលជាម្ចាស់លើទាហាននៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨១៦។

**មូលដ្ឋាន 171.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨០៨-១៧។

**មូលដ្ឋាន 172.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌដែលត្រូវចោទប្រកាន់នៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ថាស្ថានភាពរស់នៅមានការខ្វះខាតខ្លាំងបំផុត និងពុំអាចទ្រទ្រង់ទាហានបានគ្រប់គ្រាន់សម្រាប់ការងារដែលពួកគេត្រូវបំពេញឡើយ។ សូមមើលកថាខណ្ឌ ១៧៤៩, ១៧៥៤។

(b) ថ្វីបើមានកង្វះខាតសម្ភារៈទូទៅនៅក្នុងប្រទេសនៅពេលនោះក៏ដោយ ក៏លក្ខខណ្ឌនៅការដ្ឋានសាងសង់ក្នុងពេលនោះ បានបង្កើតឱ្យមានការវាយប្រហារយ៉ាងធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់ទាហាន ដែលមានភាពស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត។ សូមមើលកថាខណ្ឌ ១៨៣០-៣២, ១៨៣៥។

**មូលដ្ឋាន 173.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា វាស្ថិតនៅក្នុងអំណាចរបស់អាជ្ញាធរក្នុងការសម្រួល ឬការបញ្ចៀសនូវផលប៉ះពាល់នៃការខ្វះខាតធនធានសម្រាប់ទាហាននៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ហើយថា ការខកខានរបស់ពួកគេក្នុងការធ្វើដូចនេះ មានន័យថា ពួកគេមានចេតនាដាក់នូវលក្ខខណ្ឌយ៉ាងលំបាកទៅលើទាហាន។ សូមមើលកថាខណ្ឌ ១៨៣២, ១៨៣៦។

**មូលដ្ឋាន 174.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកើតឡើងនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨៣០-៣៧។

**មូលដ្ឋាន 175.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ក្នុងការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការបាត់ខ្លួនទាហានពីព្រលានយន្តហោះយោធាកំពង់ឆ្នាំង៖

(a) ថា ទាហានជាច្រើនបានបាត់ខ្លួនពីការដ្ឋានសាងសង់។ សូមមើលកថាខណ្ឌ ១៧៧២។

(b) ថា ទាហានជាច្រើនដែលបានបាត់ខ្លួន ត្រូវបានដកសេរីភាពដោយអជ្ញាធរបក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ១៨៤១-៤៣។

**មូលដ្ឋាន 176.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អជ្ញាធរបានលាក់បាំងព័ត៌មានដោយចេតនា ទាក់ទងនឹងការចាប់ខ្លួនកម្មករនៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨៣៩។

**មូលដ្ឋាន 177.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបាចាត់ទុកថាជាការបាត់ខ្លួនដោយបង្ខំត្រូវបានកើតឡើងនៅទីតាំងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង។ សូមមើលកថាខណ្ឌ ១៨៣៩-៤៦។

## XII. **មន្ទីរសន្តិសុខស-២១**

មូលដ្ឋានខាងក្រោមនេះចោទប្រកាន់ចំពោះកំហុសឆ្គងដែលនឹងនាំឱ្យមោឃចំពោះការផ្តន្ទាទោសទាំងអស់ ឬកំណត់ឡើងវិញលើអង្គហេតុសំខាន់ៗប្រើប្រាស់សម្រាប់ការផ្តន្ទាទោស ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ ប៉ុន្តែសម្រាប់ការទាក់ទងនឹងការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ដែលត្រូវបានបង្ហាញនៅផ្នែកដាច់ដោយឡែក:

**មូលដ្ឋាន 178.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុ ព្រមទាំងបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទងការវាយតម្លៃលើភាពអាចជឿទុកចិត្តបានលើសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោមនេះដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខស-២១៖

(a) កាំង ហ្គេកអ៊ាវ ហៅ ឌុច។ សូមមើលកថាខណ្ឌ ២០៨០-៨២។

(b) ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី។ សូមមើលកថាខណ្ឌ ២០៨៣-៨៥។

**មូលដ្ឋាន 179.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពឹងផ្អែកយ៉ាងខ្លាំងទៅនឹងប្រតិចារឹកនៃសាក្សីនានាពីសំណុំរឿង ០០១ ដែលមិនបានផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០២ ក្នុងការធ្វើការសម្រេចទាក់ទងនឹងមន្ទីរសន្តិសុខស -២១។ សូមមើលកថាខណ្ឌ ២០៨៨, ២២៣៦, ២២៣៨, ២៣៣៥, ២៣៤៣, ២៣៦៤, ២៣៦៦, ២៤៣៨, ២៤៦៤, ២៤៦៦, ២៤៩៦។

**មូលដ្ឋាន 180.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចថាបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ កសព និង កសចស ថាគួរឱ្យជឿជាក់បាន ។ សូមមើលកថាខណ្ឌ ២១១២។

**មូលដ្ឋាន 181.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុ ព្រមទាំងបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងបញ្ជីឈ្មោះទាំងឡាយនាសម័យនោះ ដែលបានយោងសម្រាប់មន្ទីរសន្តិសុខស-២១៖

(a) ក្នុងការអនុវត្តបទដ្ឋានពីរ ក្នុងការទទួលយកបញ្ជីអ្នកទោសស-២១ បញ្ជីសួរចម្លើយ និង បញ្ជីសម្លាប់ និង កំណត់ថា បញ្ជីទាំងនេះអាចជឿជាក់បាន បើទោះជាមានការខ្វះខាតក្នុងការកណត់អំពីយថាភាពរបស់វាក៏ដោយ។ សូមមើលកថាខណ្ឌ ២១១៤-១៩។

(b) ក្នុងការបដិសេធមិនផ្អែកលើបញ្ជីពីមន្ទីរសន្តិសុខស-២១ ដែលមានព័ត៌មានអំពីអ្នកទោសដែលត្រូវបានដោះលែង ផ្លាស់ប្តូរ ឬឈឺ។ សូមមើលកថាខណ្ឌ ២១១៨។

(c) ក្នុងការកំណត់ តាមបទដ្ឋានបឋម អាចជឿទុកចិត្តបានទៅលើបញ្ជីពីមន្ទីរសន្តិសុខស-២១ ដែលឯកសារទាំងនេះមានភាពស្រដៀងគ្នាគ្រប់គ្រាន់ទៅនឹងឯកសារដែលមានយថាភាព។ សូមមើលកថាខណ្ឌ ២១១៩។

(d) ក្នុងការរកឃើញថា "សៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៅស-២១" ដែលបានដាក់ជូនដោយអ្នកផលិតខ្សែ ភាពយន្ត Walter Heynowski ជាទូទៅអាចទុកចិត្តបាន ហើយពឹងផ្អែកលើវា។ សូមមើលកថាខណ្ឌ ១៣៦, ២១២៣។

**មូលដ្ឋាន 182.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការបង្កើតឱ្យមានការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងតួនាទីរបស់ ឌុច នៅមន្ទីរសន្តិសុខស-២១:

(a) ថា ឌុចមានសិទ្ធិអំណាចពេញលេញលើបុគ្គលិកមន្ទីរសន្តិសុខស-២១ទាំងអស់។ សូមមើលកថាខណ្ឌ ២១៤៩។

(b) ដែល ឌុច បានចូលរួមយ៉ាងសកម្មក្នុងការត្រួតពិនិត្យលើប្រតិបត្តិការមន្ទីរសន្តិសុខស-២១ ទាំងមូលហើយថា គាត់មានតួនាទីស្នូលក្នុងការសម្រេចចិត្តទាក់ទងនឹងការសួរចម្លើយឬការសម្លាប់អ្នកទោស។ សូមមើលកថាខណ្ឌ ២១៦០។

**មូលដ្ឋាន 183.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មន្ទីរសន្តិសុខស-២១ គឺជាកងវរសេនាធំដែលឯករាជ្យមួយដែលត្រូវបានភ្ជាប់ដោយផ្ទាល់ ហើយបានទទួលការណែនាំទាក់ទងនឹងបញ្ហាសន្តិសុខទាំងស្រុងពីគណៈកម្មាធិការអចិន្ត្រៃយ៍និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ២១៨៦, ២១៨៨, ២១៩១។

**មូលដ្ឋាន 184.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការបង្កើតឱ្យមានការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា នៅមន្ទីរសន្តិសុខស-២១:

(a) ដែល នួន ជា ធ្លាប់ជាអ្នកគ្រប់គ្រងផ្ទាល់លើ ឌុច នៅមន្ទីរសន្តិសុខស-២១ នៅពេលណាមួយ។ សូមមើលកថាខណ្ឌ ៣៤០, ៣៦២, ៣៦៩, ៥៦០, ២១៩៣។

(b) ថា នួន ជា ដឹងឮអ្នកដែលត្រូវចាប់ខ្លួន ឃុំខ្លួន និង សួរចម្លើយនៅមន្ទីរសន្តិសុខស-២១ ដែលរួមមានកម្មាភិបាលថ្នាក់ទាប ហើយមិនបានបញ្ជាឱ្យដោះលែងបុគ្គលដែលមិនមានទោសនោះទេ។ សូមមើលកថាខណ្ឌ ២២១៥។

(c) មានពេលមួយនោះ នួន ជា បានបញ្ជាឱ្យ ឌុច បញ្ជូនអ្នកទោសពី ២00 ទៅ ៣00 នាក់មកពីភូមិភាគបូព៌ាទៅជើងឯកដើម្បីសម្លាប់ភ្លាមៗ ដោយមិនបានសួរចម្លើយ។ សូមមើលកថាខណ្ឌ ២៣១១, ២៥២៧។

(d) ក្នុងការរកឃើញថា នួន ជា បានបញ្ជាឱ្យ ឌុច “យកអ្នកទោសចេញឲ្យអស់” បានបញ្ជាឱ្យសម្លាប់អ្នកទោស "លោកខាងលិច"ទាំងអស់ មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្ម ចៅ សេង និង អ្នកទោសចុងក្រោយទាំងអស់ដែលនៅសល់មុនពេលការមកដល់របស់វៀតណាមនៅខែ មករា ឆ្នាំ ១៩៧៩ ហើយបានបញ្ជាអោយចាប់ខ្លួននិងសម្លាប់ភរិយារបស់ វ៉ន វ៉េត និង ចេង អាន។ សូមមើលកថាខណ្ឌ ២៣១៨, ២៣៣២, ២៤៩៧, ២៥២៧, ២៥៥៤-៥៦។

**មូលដ្ឋាន 185.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការបង្កើតឱ្យមានការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តលើ “ខ្មាំង” នៅមន្ទីរសន្តិសុខស-២១:

(a) នៅក្នុងការបកស្រាយពាក្យស្លោករបស់បក្សកុម្មុយនិស្តកម្ពុជា និងការបោះពុម្ពផ្សាយរួមទាំងពាក្យថា "ដាច់ខាត" និង "ខ្មាំង" មានន័យថាមនុស្សទាំងអស់ត្រូវបានចាប់ខ្លួនគឺជា "ខ្មាំង" ហើយថា ស-២១ ដំណើរការដើម្បីធានាថាអ្នកទោសទទួលស្គាល់កំហុស និង ទោសរបស់ខ្លួន។ សូមមើលកថាខណ្ឌ ២១៦៣, ២៤0២។

(b) ដោយអនុលោមតាមគោលនយោបាយ បក្សកុម្មុយនិស្តកម្ពុជា បុគ្គលទាំងអស់ដែលត្រូវបានចាប់ខ្លួននិងនាំទៅមន្ទីរសន្តិសុខស-២១ ត្រូវបានកំណត់ថាជា "ខ្មាំង" ហើយត្រូវបាន "កម្ទេច"។ សូមមើលកថាខណ្ឌ ២២៣៦, ២៣៥០។

**មូលដ្ឋាន 186.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ នៅក្នុងការរកឃើញថា អ្នកទោសចំនួន ៥៨២នាក់ មកពីភូមិភាគបូព៌ាត្រូវបាន "បោសសម្អាត" នៅជើងឯក បើទោះជា ស្អួស ធី ថារឿងនេះវាមិនអាចកើតមានក៏ដោយ។ សូមមើលកថាខណ្ឌព២៥២៧។

**មូលដ្ឋាន 187.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងវាយតម្លៃពាក់ព័ន្ធនឹងការចោទប្រកាន់លើការបូបឈាម និងការធ្វើពិសោធន៍វេជ្ជសាស្ត្រនៅមន្ទីរសន្តិសុខស-២១:

(a) ថា ការអនុវត្តន៍ការបូមយកឈាមនៅមន្ទីរសន្តិសុខស -២១ ត្រូវបានយកដោយផ្ទាល់ពីអ្នកទោស ហើយបានអនុវត្តតាមរបៀបបង្ខំ ហើយជាញឹកញាប់បានស្លាប់។ សូមមើលកថាខណ្ឌ ២៤៤៦, ២៤៤៩។

(b) ខកខានក្នុងការភ្ជាប់ការបូមឈាមដែលបានចោទប្រកាន់ និងការពិសោធន៍វេជ្ជសាស្ត្រទៅលើបុគ្គលនៅមន្ទីរសន្តិសុខស-២១ ទៅនឹងគោលបំណងរួមរបស់ JCE។ សូមមើលកថាខណ្ឌ ២៥៦៤-៦៥, ២៥៦៩។

**មូលដ្ឋាន 188.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការរកឃើញពាក់ព័ន្ធនឹងការចាប់ និងសម្លាប់សមាជិកគ្រួសារ និងកូនក្មេង នៅមន្ទីរសន្តិសុខស-២១:

(a) ថា បុគ្គលដែលជាប់ទាក់ទងទៅនឹងបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ រួមទាំងសមាជិកគ្រួសារត្រូវបានចាប់ខ្លួន ហើយត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ២៣២៩-៣០, ២៣៣៣។

(b) ក្នុងការរកឃើញថាកុមារត្រូវបានឃុំឃាំង និង សម្លាប់នៅក្នុងបរិវេណមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៥១២។

**មូលដ្ឋាន 189.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការវាយតម្លៃរបស់ខ្លួន ពាក់ព័ន្ធនឹងអ្នកទោសដែលត្រូវបានដោះលែងនៅមន្ទីរសន្តិសុខស-២១:

(a) អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការបកស្រាយពាក្យ "ដោះលែង" ដែលត្រូវបានប្រើនៅក្នុងឯកសារដែលមានចំណងជើងថា "ជីវប្រវត្តិសង្ខេបនៃប្រជាជនដែលត្រូវបានដោះលែង" ដែលត្រូវបានបញ្ជូនពីមន្ទីរស -២១ ទៅកងវរសេនាតូចលេខ ៩៦ (E3/965) មានន័យថាបុគ្គលដែលបានកំណត់ត្រូវបានគេចាប់ខ្លួននិងបញ្ជូនទៅ មន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៣៤៩។

(b) ក្នុងការទាមទារឱ្យមេធាវីការពារក្តីលើកឡើងឱ្យលើសពីវិមតិសង្ស័យ និង អនុវត្តបទដ្ឋានពីរនៅក្នុងការវាយតម្លៃភ័ស្តុតាងរបស់ខ្លួនទាក់ទងនឹងការដោះលែងអ្នកទោសពីមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៣៤៥-៦២។

**មូលដ្ឋាន 190.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញឈ្មោះបុគ្គលដែលដកចេញពីបញ្ជីអ្នកទោសស-២១ មានន័យថាពួកគេត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ២២៩៦។

**មូលដ្ឋាន 191.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថា ចំនួនឆ្អឹងដែលបានរកឃើញ និង សិក្សានៅជើងឯកមិនបានតំណាងឱ្យចំនួនសរុបនៃជនរងគ្រោះនៅកន្លែងនោះទេ។ សូមមើលកថាខណ្ឌ ២៥៤០។

**មូលដ្ឋាន 192.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាយ៉ាងហោចណាស់មនុស្សចំនួន ១១ ៧៤២ នាក់ត្រូវបានសម្លាប់នៅក្នុងបរិវេណមន្ទីរស -២១ និង ទីតាំងសម្លាប់មនុស្សជើងឯក។ សូមមើលកថាខណ្ឌ ២៥៣១, ២៥៤២។

**មូលដ្ឋាន 193.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ទាក់ទងទៅនឹងការសម្លាប់ និងអំពើវិនាសកម្ម យ៉ាងហោចណាស់មនុស្សចំនួន ១១ ៧៤២ នាក់ ត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ២៥៦១-៦៩ និង២៥៧១។

**មូលដ្ឋាន 194.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការវាយតម្លៃពាក់ព័ន្ធនឹងការស្លាប់អ្នកទោសជនជាតិវៀតណាមនៅមន្ទីរសន្តិសុខស-២១:

(a) ក្នុងការអនុវត្តបទដ្ឋានពីរ ចំពោះការវាយតម្លៃអំពីភស្តុតាងរបស់ ម៉ម ណៃ ថា មិនបានដឹងពីគោលនយោបាយសម្លាប់ជនជាតិវៀតណាមនៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៤៦៦។

(b) ក្នុងការពឹងផ្អែកលើសក្ខីកម្មរបស់ ប្រាក់ ខន ដើម្បីសម្រេចថា កូនក្មេងវៀតណាម ត្រូវបានសម្លាប់ដោយទម្លាក់ពីលើអគារ។ សូមមើលកថាខណ្ឌ ២៤៧៩, ២៦២១-២២; E409/3។

(c) ដោយពឹងផ្អែកលើសក្ខីកម្មរបស់ ហ៊ីម ហ៊ុយ ស្តីអំពីខ្សែភាពយន្តដែលបង្ហាញពីការចាប់ខ្លួន និងការមកដល់របស់ទាហានវៀតណាមនៅមន្ទីរសន្តិសុខស-២១ ហើយបង្ហាញពីសាកសពរបស់ពួកគេបន្ទាប់ពីការសម្លាប់។ សូមមើលកថាខណ្ឌ ២៤៧៦។

**មូលដ្ឋាន 195.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការធ្វើទារុណកម្មជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវបានកើតឡើងទាក់ទងទៅនឹងប្រជាជនវៀតណាមដែលបានឃុំខ្លួននៅមន្ទីរសន្តិសុខស -២១។ សូមមើលកថាខណ្ឌ ២៦២១-២២។

**មូលដ្ឋាន 196.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ជាទាសករត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៥៧១-៧៣។

**មូលដ្ឋាន 197.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថា យ៉ាងហោចណាស់អ្នកទោសចំនួន ១០ ៨៨៧ នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលដំណើរការ។ សូមមើលកថាខណ្ឌ ២៥៧៧។

**មូលដ្ឋាន 198.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ពន្ធនាគារត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៥៧៥-៨៥។

**មូលដ្ឋាន 199.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានកើតឡើងទាក់ទងនឹងប្រជាជនវៀតណាម ដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៦២៩-៣០។

**មូលដ្ឋាន 200.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ថា ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានកើតឡើងទាក់ទងនឹងប្រជាជនវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៦៣៥។

**មូលដ្ឋាន 201.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថា ការប្រើពាក្យថា "ទារុណកម្ម" លើចម្លើយសារភាពស-២១ និង កំណត់ហេតុសួរចម្លើយចាំបាច់មានន័យថា ការប្រព្រឹត្តចំពោះបញ្ហា

បានកើនឡើងដល់កម្រិតនៃការឈឺចាប់ ដែលចាំបាច់ដើម្បីមានលក្ខណៈគ្រប់គ្រាន់ជាឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ សូមមើលកថាខណ្ឌ ២២៦៩, ២២៧២។

**មូលដ្ឋាន 202.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការរកឃើញតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការប្រើទារុណកម្មនៅមន្ទីរសន្តិសុខស-២១:

(a) ថា ការសន្និដ្ឋានសមហេតុសមផលតែមួយគត់ដែលអាចដកចេញពីសៀវភៅលោក ពូ ផល្លី (E3/8568) គឺថាវាបញ្ជាក់ពីការប្រើអំពើទារុណកម្មដើម្បីទទួលបានព័ត៌មានជាក់លាក់ហើយបង្ហាញថា ការសួរចម្លើយត្រូវបានធ្វើឡើងស្របតាមគោលនយោបាយពីថ្នាក់លើដើម្បីស្រង់ព័ត៌មាន និងកំណត់អត្តសញ្ញាណ "ខ្មាំង"។ សូមមើលកថាខណ្ឌ ២៤២៥-៣០។

(b) សេចក្តីណែនាំដែលហាមឃាត់ការប្រើការគំរាមកំហែង ឬ ការវាយដំ គឺផ្ទុយពីគោលនយោបាយទូទៅមួយនៅមន្ទីរសន្តិសុខស-២១ ដែលអ្នកជាប់ឃុំទាំងអស់មិនគួរទទួលបានការលើកលែង ហើយការណែនាំបែបនេះមិនត្រូវបានគោរពនោះទេ។ សូមមើលកថាខណ្ឌ ២៣៦៨។

(c) ជនជាប់ឃុំនៅស-២១ ត្រូវបានគេធ្វើទារុណកម្ម នៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែលរួមមាន នួន ជា។ សូមមើលកថាខណ្ឌ ២៥៩៧, ៣៩៨១។

**មូលដ្ឋាន 203.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុ អំពើទារុណកម្មនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបង្កើតនៅមន្ទីរសន្តិសុខស-២១។ សូមមើល ២៥៨៦-៩៧។

**មូលដ្ឋាន 204.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការរកឃើញថា អំពើទារុណកម្មគឺជាអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានបង្កើតទាក់ទងនឹងជនជាតិវៀតណាមដែលជាប់ឃុំ នៅមន្ទីរសន្តិសុខស-២១។ សូមមើល កថាខណ្ឌ ២៦២៤។

**មូលដ្ឋាន 205.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការរកឃើញថាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបង្កើតនៅមន្ទីរសន្តិសុខស-២១ ប្រឆាំងនឹងក្រុមនយោបាយជាក់លាក់។ សូមមើល ២៥៩៩-៦០៤។

**មូលដ្ឋាន 206.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការរកឃើញថា ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ ដោយសារតែមូលហេតុជាតិសាសន៍។ សូមមើល កថាខណ្ឌ ២៦០៧-១០។

**មូលដ្ឋាន 207.** អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការ វាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌឃុំខ្លួននៅមន្ទីរសន្តិសុខស-២១:

(a) ថា តើលក្ខខណ្ឌនៃការឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ត្រូវបានបង្កើតឡើងយ៉ាងខ្លោចផ្សារ ឬជាមធ្យោបាយនៃការដាក់ទណ្ឌកម្មដែលមិនជាប់ពាក់ព័ន្ធនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ សូមមើលកថាខណ្ឌ ២៣៧១។

(b) ក្នុងការវាយតម្លៃអំពីភ័ស្តុតាងរបស់ ឌុច ទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួននៅពន្ធនាគារពិសេស។ សូមមើលកថាខណ្ឌ ២៦១៨។

**មូលដ្ឋាន 208.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើឃាតកម្មនៅក្នុងទំរង់ដោយចេតនាដឹងទុកជាមុន ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៥៦៤-៦៥។

**មូលដ្ឋាន 209.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ និង កន្លែងឃុំឃាំងពិសេស។ សូមមើលកថាខណ្ឌ ២៦១២-១៧។

**មូលដ្ឋាន 210.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ការប្រព្រឹត្តដោយអមនុស្សធម៌ថា ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានកើតឡើងទាក់ទងទៅនឹងប្រជាជនវៀតណាមដែលបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៦២៦។

**មូលដ្ឋាន 211.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ចេតនាធ្វើឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ឬ រងរបួសធ្ងន់ធ្ងរដល់រាងកាយ ឬ សុខភាពដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានកើតឡើងទាក់ទងទៅនឹងប្រជាជនវៀតណាមឃុំខ្លួននៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៦២៧-២៨។

## XIII. មន្ទីរសន្តិសុខក្រាំងតាចាន់

មូលដ្ឋានខាងក្រោមនេះជាកំហុស ដែលនឹងធ្វើឱ្យមោឃរាល់ការផ្តន្ទាទោសទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែចំពោះបញ្ហាពាក់ព័ន្ធនឹងការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងវៀតណាម និងការពឹងផ្អែករបស់អង្គជំនុំជម្រះទៅលើ "កំណត់ត្រាស្រុកតាំក្រក់" នឹងត្រូវបង្ហាញនៅក្នុងផ្នែកដាច់ដោយឡែក:

**មូលដ្ឋាន 212.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ហើយបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃភាពជឿជាក់ និងភាពគួរឲ្យជឿទុកចិត្តបានរបស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់ភស្តុតាងពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ដូចខាងក្រោម:

(a) ថា អាចអនុវត្តបទដ្ឋានពីរចំពោះការវាយតម្លៃភាពគួរឲ្យជឿទុកចិត្តបាននៃសក្ខីកម្មរបស់អតីតឆ្មាំ សូត្រ សាំង, វ៉ាន់ សឿន និង ស្រី ថន។ សូមមើលកថាខណ្ឌ ២៦៥៣-៦៧។

(b) សក្ខីកម្មរបស់ មាស សុខា គឺគួរឱ្យជឿជាក់ និង គួរឲ្យជឿទុកចិត្តបាន។ សូមមើលកថាខណ្ឌ ២៦៦៨-៧៤។

(c) ភស្តុតាងដែលមិនបានស្បថរបស់ សយ សែន ថាគួរឱ្យជឿជាក់ និង គួរឲ្យជឿទុកចិត្តបាន។ សូមមើលកថាខណ្ឌ ២៦៧៧-៨២។

**មូលដ្ឋាន 213.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញភូមិភាគនិរតីមានការដឹងឮ និង គ្រប់គ្រងមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយព័ត៌មាននោះត្រូវបានបញ្ជូនទៅភូមិភាគ តាមរយៈតំបន់ ១៣។ សូមមើលកថាខណ្ឌ ២៧០៩។

**មូលដ្ឋាន 214.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការចាប់ខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់:

(a) ថា អាចពឹងផ្អែកលើកំណត់ត្រាស្រុកត្រាំកក់ ដើម្បីកំណត់ប្រភេទនៃបទល្មើស ដែលអ្នកទោសត្រូវបានចាប់ខ្លួន។ សូមមើលកថាខណ្ឌ ២៧១៧-២៩, ២៧៧០។

(b) ទំនាក់ទំនងជាមួយគ្រួសារ គឺជាមូលហេតុមួយសម្រាប់ការចាប់ខ្លួន និង សម្លាប់។ សូមមើលកថាខណ្ឌ ២៨០១។

(c) ថាកម្រិតអប់រំ និង រូបរាង នៃអតីតអ្នកជាប់ឃុំឃាំង វង្ស សារុន និង សុខមាលភាពរបស់ស្វាមីមានន័យថា គាត់មិនអាចជាប់គុកដោយសារការចូលរួមរបស់គាត់ក្នុងសកម្មភាពខុសច្បាប់។ សូមមើលកថាខណ្ឌ ២៧៥០។

**មូលដ្ឋាន 215.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការឃុំឃាំងត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨២៥-២៧។

**មូលដ្ឋាន 216.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការរំលោភផ្លូវភេទ:

(a) ថាឧក្រិដ្ឋកម្មផ្លូវភេទត្រូវបានប្រព្រឹត្តឡើង។ សូមមើលកថាខណ្ឌ ២៧៣៥-៣៨។

(b) តារាសំដែង គឹម ណូវ៉ា ត្រូវបានគេរំលោភ ហើយត្រូវបានគេសម្លាប់នៅទីនោះរួមជាមួយប្តីរបស់នាងឈ្មោះ ណុប ណែម និង កូនរបស់ពួកគេ។ សូមមើលកថាខណ្ឌ ២៧៣៨។

(c) ថាស្ត្រីពីរនាក់មកពីកងចល័តមួយត្រូវបានចាប់រំលោភដោយឆ្មាំគុក ឈ្មោះ ស្រី ផន និង សាំង។ សូមមើលកថាខណ្ឌ ២៧៦១, ២៧៦៤។

**មូលដ្ឋាន 217.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃឃាតកម្មនៅក្នុងទំរង់ដោយចេតនាដឹងទុកជាមុន ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨១៥-១៧។

**មូលដ្ឋាន 218.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន។ សូមមើលកថាខណ្ឌ ២៨២២-២៣។

**មូលដ្ឋាន 219.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃសកម្មភាពអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨៤៩-៥១។

**មូលដ្ឋាន 220.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់:

(a) ថាអ្នកទោសខ្លះត្រូវបានគេសម្លាប់ភ្លាមៗ បន្ទាប់ពីបានទៅដល់ ដោយពុំមានការសួរចម្លើយ ជាពិសេសក្រុមមនុស្សជាង១០០នាក់។ សូមមើលកថាខណ្ឌ ២៧៥២, ២៧៥៩។

(b) ថា អាចមើលឃើញបន្ទប់សួរចម្លើយពីខាងក្រៅ។ សូមមើលកថាខណ្ឌ ២៦៩២។

(c) អំពើហិង្សា និង ការគំរាមកំហែងនៃអំពើហិង្សាត្រូវបានគេប្រើដើម្បីទទួលបានចម្លើយសារភាពពីអ្នកទោស រួមទាំងការប្រើរំពាត់ ដំបង ដង្កាប់ និង ថង់ប្លាស្ទិច។ សូមមើលកថាខណ្ឌ ២៧៤៤-៤៧។

(d) ថា អ្នកទោសខ្លះ ត្រូវបានធ្វើបាបរហូតដល់ស្លាប់។ សូមមើលកថាខណ្ឌ ២៧៤៤-៤៩។

**មូលដ្ឋាន 221.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្មត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨២៩-៣២។

**មូលដ្ឋាន 222.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយមូលហេតុនយោបាយត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ប្រឆាំងនឹង "ខ្មាំងពិតប្រាកដ ឬខ្មាំងត្រូវបានគិតទុក" របស់បក្សកុម្មុយនិស្តកម្ពុជា ដែលរួមមានប្រជាជនថ្មី។ សូមមើលកថាខណ្ឌ ២៨៤៣។

**មូលដ្ឋាន 223.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់:

(a) ថាមានការសម្លាប់ជាទៀងទាត់។ សូមមើលកថាខណ្ឌ ២៧៧១។

(b) ការដោះលែងអ្នកទោសទាំងនោះគឺមិនអាចកើតមានទេ ហើយការសម្លាប់គឺជាច្បាប់។ សូមមើលកថាខណ្ឌ ២៧៧០។

(c) បុគ្គលិកអាចកំណត់អត្តសញ្ញាណអ្នកទោសជាប្រជាជនថ្មី ហើយប្រភពនេះគឺជាកត្តាសម្រេច ក្នុងការកំណត់វាសនារបស់ពួកគេ។ សូមមើលកថាខណ្ឌ ២៧៩៥។

(d) ថាទារកម្នាក់ត្រូវបានសម្លាប់ដោយត្រូវបានវាយផ្ទប់នឹងដើមឈើ។ សូមមើលកថាខណ្ឌ ២៧៥២។

(e) ថាកុមារពីរនាក់ត្រូវបានសម្លាប់ដោយឆ្នាំគុក ដែលគេស្គាល់ថាជា សៀង និង សាំង។ សូមមើលកថាខណ្ឌ ២៧៦៦, ២៧៦៨។

(f) ថា ចម្រៀងខ្លាំងៗ ត្រូវបានចាក់តាមម៉េក្រូដើម្បីកុំឲ្យឮសម្លេងរំខាននៃការសម្លាប់នេះ។ សូមមើលកថាខណ្ឌ ២៧៧២។

(g) ថាសរីរាង្គមនុស្សត្រូវបានបរិភោគដោយឆ្នាំគុក។ សូមមើលកថាខណ្ឌ ២៧៧៦។

**មូលដ្ឋាន 224.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការស្លាប់ជាទូទៅនៅមន្ទីរសន្តិសុខក្រាំងតាចាន់:

(a) ថាភាគច្រើននៃអដ្ឋិធាតុ ត្រូវបានពិនិត្យដោយ វឿន វុទ្ធី នៅទីតាំងមន្ទីរសន្តិសុខក្រាំងតាចាន់គឺនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ សូមមើលកថាខណ្ឌ ២៧៨១, ២៧៨៥។

(b) ដែលយ៉ាងហោចណាស់មនុស្សជាង ១០០០ នាក់ត្រូវបានសម្លាប់ ឬស្លាប់ នៅរវាងឆ្នាំ ១៩៧៥ និង ១៩៧៩។ សូមមើលកថាខណ្ឌ ២៨០៧។

**មូលដ្ឋាន 225.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត និងការសម្លាប់រង្គាលបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨១២-១៤។

**មូលដ្ឋាន 226.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការប្រព្រឹត្តដែលបានកំណត់ថា ការបាត់ខ្លួនត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ២៨៥៣-៥៨។

## XIV. មន្ទីរសន្តិសុខអូរកន្សែង

មូលដ្ឋានខាងក្រោមនេះជាកំហុស ដែលនឹងធ្វើឱ្យមោឃៈដល់រាល់ការផ្តន្ទាទោសទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខអូរកន្សែង តែសម្រាប់ការប្រព្រឹត្តលើជនជាតិវៀតណាមត្រូវបានបង្ហាញ ដាច់ដោយឡែកៈ

**មូលដ្ឋាន 227.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា សុន សេន ត្រូវបានដឹងអំពីស្ថានភាពនៅមន្ទីរសន្តិសុខអូរកន្សែង ដែលគាត់គ្រប់គ្រងជាទូទៅ ហើយថា សុន សេន បានបញ្ជូនព័ត៌មានជាទៀងទាត់ទៅ "អង្គការ" មុនពេលផ្តល់ការណែនាំដល់ថ្នាក់ក្រោម ដែលរួមមានមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៨៧៣-៧៥។

**មូលដ្ឋាន 228.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថា គោលបំណងរបស់មន្ទីរសន្តិសុខអូរកន្សែង គឺដើម្បីយកចម្លើយសារភាពហើយបោសសម្អាត "ខ្មាំង" ហើយថាបើទោះបីជាត្រូវបានចាប់ខ្លួន "ក្រោមលេស" ឧក្រិដ្ឋកម្មធម្មតា ឬ បទឧក្រិដ្ឋក៏ដោយ ក៏អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខត្រូវបាន

ឃាត់ខ្លួនពីព្រោះពួកគេត្រូវបានគេគិតថា ជា"ខ្មាំង"។ សូមមើលកថាខណ្ឌ ២៨៨៧, ២៨៩៨-៩០០, ២៩៧៨។

**មូលដ្ឋាន 229.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា បុគ្គលត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែងដោយមូលដ្ឋាននៃសមាជិកភាពរបស់ពួកគេជាមួយក្រុមនយោបាយ។ សូមមើលកថាខណ្ឌ ២៩៨៣-៩០, ២៨៩៥, ២៨៩៩, ២៩០៥-០៦។

**មូលដ្ឋាន 230.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៩៨១-៩៣។

**មូលដ្ឋាន 231.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ដោយខកខាន ក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីចំពោះមូលដ្ឋានអង្គហេតុស្របច្បាប់ ចំពោះការចាប់ខ្លួន និង ការឃុំឃាំងបុគ្គលនានានៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៩៧៦។

**មូលដ្ឋាន 232.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មានការរំលោភបំពានលើសិទ្ធិនីតិវិធីជាក់លាក់របស់បុគ្គលដែលត្រូវបានឃាត់ខ្លួននៅមន្ទីរសន្តិសុខអូរកន្សែង ហើយថាការរំលោភបែបនេះនាំឲ្យមានការឃុំខ្លួនដោយខុសច្បាប់។ សូមមើលកថាខណ្ឌ ២៨៩៣, ២៨៩៥, ២៨៩៧, ២៨៩៩, ២៩៧៦-៧៩។

**មូលដ្ឋាន 233.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការឃុំឃាំងជនស៊ីវិលនៅមន្ទីរសន្តិសុខអូរកន្សែងពុំមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ឡើយ។ សូមមើលកថាខណ្ឌ ២៨៩៩, ២៩៧៨។

**មូលដ្ឋាន 234.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការឃុំខ្លួនត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៩៧៦-៧៩។

**មូលដ្ឋាន 235.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញថា ពលកម្មដែលអនុវត្តដោយជនជាប់ឃុំនៅមន្ទីរសន្តិសុខអូរកន្សែងត្រូវបានធ្វើឡើងដោយខុសច្បាប់។ សូមមើលកថាខណ្ឌ ២៩៧០។

**មូលដ្ឋាន 236.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អាជ្ញាធរនៅមន្ទីរសន្តិសុខអូរកន្សែងបានដាក់របបធ្វើការលើជនជាប់ឃុំដោយចេតនាដើម្បីបន្ទាបបន្ថោកពួកគេទៅជាទំនិញតែប៉ុណ្ណោះ ដែលធ្វើឱ្យមានការកេងប្រវ័ញ្ចនិង ជិះជាន់ ដើម្បីជាប្រយោជន៍ដល់ បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ២៩១០-១១, ២៩១៥, ២៩១៩, ២៩៧១-៧៤។

**មូលដ្ឋាន 237.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៩៧០-៧៤។

**មូលដ្ឋាន 238.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ស្ថានភាពឃុំឃាំងនៅមន្ទីរសន្តិសុខអូរកន្សែងបានកើនឡើងជាទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដទៃទៀត។ សូមមើលកថាខណ្ឌ ៣០០៤-០៧, ៣០០៩។

**មូលដ្ឋាន 239.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អាជ្ញាធរនៅមន្ទីរសន្តិសុខអូរកន្សែងបានធ្វើឱ្យមានការឈឺចាប់ខាងរាងកាយ និងផ្លូវចិត្តលើជនជាប់ឃុំឃាំង។ សូមមើលកថាខណ្ឌ ៣០០៨។

**មូលដ្ឋាន 240.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ៣០០៤-១០។

**មូលដ្ឋាន 241.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុនៅក្នុងការរកឃើញខាងក្រោមរបស់ខ្លួនទាក់ទងនឹងការសម្លាប់ជនជាតិចារ៉ាយនៅមន្ទីរសន្តិសុខអូរកន្សែង:

(a) ថា ក្រុមមួយចារ៉ាយប្រហែល ១០០ នាក់ត្រូវបានយកទៅអូរកន្សែង ហើយត្រូវបានសម្លាប់ជាច្រើន។ សូមមើលកថាខណ្ឌ ២៩៥១-៥៦, ២៩៦០, ២៩៦៨។

(b) ថាជនជាតិចាម៉ាយ ១០០ នាក់ដែលត្រូវបានសម្លាប់ គឺជាផ្នែកមួយនៃក្រុមចាម៉ាយ ២០៩នាក់ ដែលត្រូវបានគេរាយការណ៍ថា ត្រូវបានចាប់ខ្លួនដោយកងកម្លាំងកងពលលេខ ៨០១ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧។ សូមមើលកថាខណ្ឌ ២៩៣៥-៤៥, ២៩៦០។

(c) ថា ការបញ្ជាឱ្យសម្លាប់ចាម៉ាយ ១០០នាក់ ត្រូវបានបញ្ជូនតាម សុន សេន និង សៅ សារឿន ទៅកាន់បុគ្គលិកនៅអូរកន្សែង ដោយមានការចូលរួមពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ២៩៧៥, ២៩៦០។

**មូលដ្ឋាន 242.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុនៅក្នុងការរកឃើញខាងក្រោមរបស់ខ្លួនទាក់ទងនឹងការស្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង:

(a) ថា ជនជាប់ឃុំបីនាក់ត្រូវបានគេសម្លាប់នៅជម្លោះពីរដាច់ដោយឡែកពីគ្នាជាមួយឆ្នាំ។ សូមមើលកថាខណ្ឌ ២៩២៦, ២៩៦៣។

(b) អ្នកទោសយោធាម្នាក់ និង អ្នកទោសស្រីម្នាក់ត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ២៩២៩, ២៩៣២, ២៩៦៤។

(c) ថា ស្ថានឃុំឃាំងនេះបាននាំឱ្យមានការស្លាប់របស់ជនជាប់ឃុំឃាំង។ សូមមើលកថាខណ្ឌ ២៩១៦-១៨, ២៩៣៤, ២៩៦៥។

**មូលដ្ឋាន 243.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត និង ការសម្លាប់រង្គាល ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង។ សូមមើលកថាខណ្ឌ ២៩៦១-៦៨។

## XV. មន្ទីរសន្តិសុខភ្នំក្រោល

មូលដ្ឋានកំហុសខាងក្រោមនេះ ដែលនឹងនាំឱ្យមោឃចំពោះការផ្តន្ទាទោសទាំងអស់ដែលទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល:

**មូលដ្ឋាន 244.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ដោយពិចារណាលើភស្តុតាងទាក់ទងនឹងព្រឹត្តការណ៍ខាងក្រៅវិសាលភាព ដើម្បីការរកឃើញទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣០៥១-៦៥, ៣០៨០, ៣១៣៧-៥១។

**មូលដ្ឋាន 245.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ដោយពិចារណាលើភស្តុតាងដែលទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល ដើម្បីធ្វើការរកឃើញទាក់ទងនឹងព្រឹត្តិការណ៍ដែលនៅក្រៅវិសាលភាពនៃដីការដំណោះស្រាយ។ សូមមើលកថាខណ្ឌ ៣០៦០។

**មូលដ្ឋាន 246.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវាយតម្លៃភស្តុតាងរបស់ខ្លួនទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល។

(a) ក្នុងការរកឃើញថា សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃដូចគ្នានឹងសក្ខីកម្មរបស់សាក្សីដែរ។ សូមមើលកថាខណ្ឌ ៣០៦៦។

(b) ក្នុងការរកឃើញដោយផ្អែកតែលើភស្តុតាងដែលមិនត្រូវបានស្បថ។ សូមមើលកថាខណ្ឌ ៣១០១។

(c) នៅក្នុងការរកឃើញ ដោយផ្អែកលើចម្លើយនៅក្រៅតុលាការ។ សូមមើលកថាខណ្ឌ ៣១០៥-០៦, ៣១១០។

**មូលដ្ឋាន 247.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវាយតម្លៃភស្តុតាងរបស់ខ្លួនទាក់ទងនឹងប្រព័ន្ធទំនាក់ទំនង និង ការវាយការណ៍ នៅមន្ទីរសន្តិសុខភ្នំក្រោល។

(a) ថា លេខាតំបន់១០៥ ឡាំង បានរាយការណ៍ដោយផ្ទាល់ដល់ថ្នាក់ដឹកនាំ ហើយទទួលបានការណែនាំដោយផ្ទាល់ពី ប៉ុល ពត និង នួន ជា មកវិញ។ សូមមើលកថាខណ្ឌ ៣០៣៦។

(b) ថា បញ្ជាឱ្យចាប់ខ្លួន ឃុំខ្លួន និង សម្លាប់បុគ្គលិកតំបន់ ១០៥ ត្រូវបានធ្វើឡើងដោយអាជ្ញាធរ និង ដឹងឮដោយថ្នាក់ដឹកនាំ។ សូមមើលកថាខណ្ឌ ៣០៨០។

**មូលដ្ឋាន 248.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ នៅក្នុងការវាយតម្លៃភស្តុតាងរបស់ខ្លួនទាក់ទងនឹងការឃុំឃាំង និង លក្ខខណ្ឌការងារនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១០២, ៣១០៥-០៦។

**មូលដ្ឋាន 249.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់នៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១១៥, ៤១៧៤។

**មូលដ្ឋាន 250.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងដោយមានចេតនាដឹងទុកជាមុន ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១១៦, ៤១៨៦។

**មូលដ្ឋាន 251.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការផ្តន្ទាទោស នួន ជា ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំក្រោល បន្ទាប់ពីបានរកឃើញថា ឧក្រិដ្ឋកម្មនេះមិនត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១១៨, ៤១៧៤។

**មូលដ្ឋាន 252.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃទាសភាពត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១២១-២៦។

**មូលដ្ឋាន 253.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការឃុំខ្លួនត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១២៨-៣១។

**មូលដ្ឋាន 254.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១៣៧-៥១។

**មូលដ្ឋាន 255.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១៥៣-៥៩។

**មូលដ្ឋាន 256.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ថា ជាការបាត់ខ្លួនត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល។ សូមមើលកថាខណ្ឌ ៣១៦១-៦៦។

## XVI. ការប្រព្រឹត្តលើពុទ្ធសាសនិក

មូលដ្ឋានខាងក្រោមនេះចោទប្រកាន់ចំពោះកំហុសឆ្គងដែលនឹងនាំឱ្យមោឃចំពោះការផ្តន្ទាទោសទាំងអស់ដែលទាក់ទងនឹងការប្រព្រឹត្តលើពុទ្ធសាសនិក:

**មូលដ្ឋាន 257.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយ បក្សកុម្មុយនិស្តកម្ពុជា ទៅលើពុទ្ធសាសនិក:

(a) ក្នុងការរកឃើញថា មានបញ្ហាច្បាស់លាស់មួយដែលបានលើកឡើងបន្ទាប់ពីកិច្ចប្រជុំ បក្សកុម្មុយនិស្តកម្ពុជាមួយនៅក្នុងរាជធានីភ្នំពេញនៅខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីលុបបំបាត់ពុទ្ធសាសនាពីសង្គមកម្ពុជាតាមរយៈការខិតខំប្រឹងប្រែងដោយមានគម្រោង មានការរៀបចំ និង ដោយរីករាលដាល។ សូមមើលកថាខណ្ឌ ១០៨៧-៨៩។

(b) ក្នុងការរកឃើញថា បក្សកុម្មុយនិស្តកម្ពុជាមានចេតនាលុបបំបាត់ពុទ្ធសាសនាពីសង្គមកម្ពុជា ហើយថា ការផ្សឹកព្រះសង្ឃគឺជាមធ្យោបាយចេតនាដើម្បីសម្រេចគោលបំណងនេះ។ សូមមើលកថាខណ្ឌ ១០៩៣, ៤០១៥-១៦, ៤០២១។

(c) សេចក្តីថ្លែងការណ៍មួយ ដែលធ្វើឡើងដោយព្រះមហាក្សត្រព្រះវររាជបិតានរោត្តមសីហនុ ដែលបានបញ្ជាក់ថាការផ្សឹកព្រះសង្ឃត្រូវបានគ្រោងឡើង រៀបចំ និង រីករាលដាល។ សូមមើលកថាខណ្ឌ ១០៨៩, ៤០១៥។

**មូលដ្ឋាន 258.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ការប្រតិបត្តិព្រះពុទ្ធសាសនាត្រូវបានហាមឃាត់នៅក្នុងស្រុកត្រាំកក់។ សូមមើលកថាខណ្ឌ ១១០៧-០៨។

**មូលដ្ឋាន 259.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការប្រព្រឹត្តលើពុទ្ធសាសនិកនៅស្រុកត្រាំកក់:

(a) ថាការបង្កើតគណៈកម្មាធិការខេត្តមួយនៅវត្តអង្គរកា គឺជាការប៉ុនប៉ងលួងលោមព្រះសង្ឃដែលត្រូវបានផ្សឹក។ សូមមើលកថាខណ្ឌ ១០៩៥។

(b) ព្រះសង្ឃត្រូវបានប្រមូលនៅវត្តអង្គរកា និង ត្រូវបានផ្សឹក។ សូមមើលកថាខណ្ឌ ១០៩៤, ១០៩៨-១០០។

**មូលដ្ឋាន 260.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិក:

(a) ថា មានការវាយប្រហារដែលបានរៀបចំឡើង និង ប្រឆាំងជាប់នឹងសាសនានៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ១១៨៥។

(b) ថា ព្រះសង្ឃពុទ្ធសាសនាត្រូវបានបង្ខំឱ្យបោះបង់ចោលជំនឿរបស់ខ្លួន។ សូមមើលកថាខណ្ឌ ១១៨៥។

**មូលដ្ឋាន 261.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើសាសនាត្រូវបានកើតឡើងនៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១១៨៣-៨៧។

## XVII. ការប្រព្រឹត្តលើជនជាតិចាម

មូលដ្ឋានខាងក្រោមនេះគឺជាកំហុស ដែលនឹងនាំឱ្យមោឃចំពោះការផ្តន្ទាទោសទាំងអស់ដែលទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម តែសម្រាប់ការដ្ឋានការងារទំនប់ ១ មករា ដែលនឹងបង្ហាញនៅផ្នែកដាក់ដោយឡែក:

**មូលដ្ឋាន 262.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ការខកខានមិនឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងការដកមន្ទីរសន្តិសុខក្រូចឆ្មារចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលនាំឱ្យអវត្តមាននៃភស្តុតាងសំខាន់ៗ រួមមានការផ្តល់សក្ខីកម្មរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងអ្នកដទៃទៀតដែលជាប់ពាក់ព័ន្ធក្នុងការបង្ក្រាបការបះបោរនៅឆ្នាំ ១៩៧៥ និងការស៊ើបអង្កេតទៅលើចលនាបះបោល ដែលពាក់ព័ន្ធនឹងជនជាតិចាម និង ខ្មែរ។ សូមមើលកថាខណ្ឌ ៣១៧៤, E៤៣៩/៥។

**មូលដ្ឋាន 263.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ដោយបន្ថែមវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយបានរកឃើញថា ចាមដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខក្រូចឆ្មា នៅបន្ទាប់ពីការបះបោរឆ្នាំ ១៩៧៥ ត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ៣២៥៨។

**មូលដ្ឋាន 264.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុនៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពគួរឱ្យជឿទុកចិត្ត និង ភាពជឿជាក់នៃសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម ដូចខាក្រោម:

(a) នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពគួរឱ្យជឿជាក់របស់ សុះ កំរី និង គ្មានការពិចារណាអវិជ្ជមានណាមួយទាក់ទងទៅនឹងការស្ទាក់ស្ទើររបស់គាត់ក្នុងការមកផ្តល់សក្ខីកម្ម និង ការបិដសេធរបស់គាត់ក្នុងការស្បថនៅចំពោះមុខគម្ពីរគួរអាន។ សូមមើលកថាខណ្ឌ ៣១៨៥។

(b) នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពអាចទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយលើកទី១របស់ ប្រាក់ យុត។ សូមមើលកថាខណ្ឌ ៣១៩១។

(c) នៅក្នុងការវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន និង ការពឹកងផ្អែកយ៉ាងច្រើនទៅលើភស្តុតាងរបស់គាត់។ សូមមើលកថាខណ្ឌ ៣២១៧, ៣២១៨, ៣២៣០, ៣២៣៩, ៣២៤២, ៣២៥១, ៣២៦៧, ៣២៩៣-៩៥។

(d) នៅក្នុងសវនាការស្តាប់ចម្លើយសាក្សីអ្នកជំនាញ អ៊ីសា ឧស្មន។ សូមមើលកថាខណ្ឌ ៣១៩២។

(e) ក្នុងការរកឃើញថា សេចក្តីសង្ខេបភស្តុតាងដែលប្រមូលបានរបស់ អ៊ីសា ឧស្ម័ន ជាទូទៅអាចជឿជាក់បាន។ សូមមើលកថាខណ្ឌ ៣១៩៦។

**មូលដ្ឋាន 265.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា កែ ពក លេខាភូមិភាគកណ្តាល (អតីត) ឧត្តរ បានបញ្ជូនរបាយការណ៍ជាទៀងទាត់ទៅ "មជ្ឈិមបក្ស" ហើយស្រុកបានរាយការណ៍ដោយផ្ទាល់ទៅ កែ ពក។ សូមមើលកថាខណ្ឌ ៣២០២។

**មូលដ្ឋាន 266.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា បក្សកុម្មុយនិស្តកម្ពុជា មិនបានអនុវត្តសេរីភាពខាងសាសនា និង ចាត់ទុកថាសាសនាអ៊ីស្លាមជាសាសនាប្រតិកិរិយា ហើយហាមឃាត់ការប្រតិបត្តិ។ សូមមើលកថាខណ្ឌ ៣២១៥។

**មូលដ្ឋាន 267.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុដូចខាងក្រោមនេះ ដើម្បីឈានទៅដល់ការសន្និដ្ឋានរបស់ខ្លួនថា បក្សកុម្មុយនិស្តកម្ពុជា បានគាំទ្រ "ពូជសាសន៍សុទ្ធ" ពោលគឺដើម្បីរក្សា "ពូជសាសន៍ខ្មែរតែមួយ" ដោយការបំបាត់ពូជ និង ជាតិសាសន៍ភាគតិចចោល មានដូចជាចាមជាដើម:

(a) នៅក្នុងការយោងទៅ "ជាតិសាសន៍ខ្មែរ" នៅក្នុងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនិស្តកម្ពុជា បានបង្ហាញការដកចេញនៃជនជាតិភាគតិច និងជាតិសាសន៍ភាគតិច។ សូមមើលកថាខណ្ឌ ៣២១៦។
(b) ដោយពឹងផ្អែកលើភស្តុតាងនៃសាក្សីទៅលើអង្គហេតុ ឬ ដើមបណ្តឹងរដ្ឋប្បវេណី និង ភស្តុតាងដែលមិនបានដេញដោល ដែលបញ្ជាក់ថា បក្សកុម្មុយនិស្តកម្ពុជា បានដាក់គោលដៅទៅលើជនជាតិចាម ដើម្បីរួមបញ្ចូលពួកគេទៅជាខ្មែរតែមួយ។ សូមមើលកថាខណ្ឌ ៣២១៧-១៩។
(c) ដោយពឹងផ្អែកលើទស្សនៈមិនត្រឹមត្រូវរបស់ "អ្នកជំនាញ" ដែលអ្នកខ្លះបានផ្តល់សក្ខីកម្ម ឬ ក៏មិនបានផ្តល់សក្ខីកម្មជាអ្នកជំនាញ។ សូមមើលកថាខណ្ឌ ៣២១៩។

**មូលដ្ឋាន 268.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការដកស្រង់ពីរបាយការណ៍នៃសកម្មភាពខុសច្បាប់ ដែលពាក់ព័ន្ធនឹងជនជាតិចាមដែលស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងជិតដល់។ សូមមើលកថាខណ្ឌ ៣២១៤, ៣២៣០។

**មូលដ្ឋាន 269.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងវិធីសាស្ត្រដូចខាងក្រោមរបស់ខ្លួនចំពោះភស្តុតាងដោះបន្ទុកដ៏លើសលប់ ដែលថាគ្មានគោលនយោបាយរបស់រដ្ឋក្នុងការដាក់គោលដៅលើចាមដូច្នោះទេ:

(a) ក្នុងការបដិសេធភស្តុតាងដ៏ស៊ីសង្វាក់គ្នារបស់ ប្រាក់ យុត និង យូ វ៉ាន់ ដែលថា ចាមត្រូវបានដាក់គោលដៅដោយសារសកម្មភាពមិនស្របច្បាប់ គឺមិនមែនដោយសារតែអត្តសញ្ញាណរបស់ពួកគេឡើយ។ សូមមើលកថាខណ្ឌ ៣២២១។

(b) ក្នុងការបដិសេធភស្តុតាងរបស់ បាន សៀក និង ការបកស្រាយមិនត្រឹមត្រូវទូវភស្តុតាងរបស់ វ៉ាន់ ម៉ាត ដែលបង្ហាញយ៉ាងស៊ីសង្វាក់ថា សេចក្តីណែនាំរបស់ កែ ពក ឲ្យ "បោសសំអាត" ពួកខ្មាំង ដោយមិនគិតពីជាតិពន្ធុរបស់ពួកគេ។ សូមមើលកថាខណ្ឌ ៣២២៣-២៤, ៣២៧៣។

(c) ក្នុងការបដិសេធភស្តុតាងរបស់ ឌុច, នៅក្នុងភស្តុតាងស៊ីសង្វាក់គ្នារបស់ ទេព ប៉ូច និង ពេជ្រ ជឹម ថាពុំមានផែនការដើម្បី "បោសម្អាត" ជនជាតិចាមឡើយ។ សូមមើលកថាខណ្ឌ ៣២២៣, ៣២២៥។

**មូលដ្ឋាន 270.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការសន្និដ្ឋានថា ដើម្បីបង្កើតសង្គមដែលគ្មានសាសនា និងសង្គមតែមួយនោះ បក្សកុម្មុយនិស្តកម្ពុជា បានដាក់គោលដៅទៅលើជនជាតិចាម ជាក្រុមជនជាតិសាសន៍ និង សាសនា ហើយការអនុវត្តគោលនយោបាយនេះរួមមានការរឹតត្បិតលើវប្បធម៌ចាម ការបង្ក្រាបការបះបោររបស់ចាម ការបង្ខំឱ្យមានការផ្លាស់ប្តូរទីលំនៅ និងការសម្លាប់ជនជាតិចាម។ សូមមើលកថាខណ្ឌ ៣២២៧-២៨។

**មូលដ្ឋាន 271.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ថ្នាក់ដឹកនាំ បក្សកុម្មុយនិស្តកម្ពុជា នៅកោះផល បានប្រកាស រឹតបន្តឹងប្រាំយ៉ាងទៅលើវប្បធម៌ចាម នៅខែ កញ្ញា ឆ្នាំ ១៩៧៥។ សូមមើលកថាខណ្ឌ ៣២៥៣។

**មូលដ្ឋាន 272.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ការខកខានក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី និង ភ័ស្តុតាងពាក់ព័ន្ធ ដែលថាការរឹតត្បិតលើវប្បធម៌ចាមគឺជាគោលនយោបាយសង្គម ដែលអនុវត្តដូចគ្នាទៅនឹងប្រជាជនកម្ពុជាទាំងមូល ហើយថាពួកគេមិនត្រូវបានកំណត់ដោយមានចេតនារើសអើងលើមូលដ្ឋានសាសនា ឬ ជនជាតិភាគតិចឡើយ។ សូមមើលកថាខណ្ឌ ៣២៣៨, ៣២៤៥, ៣២៥០, ៣៣២៩។

**មូលដ្ឋាន 273.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មានករណីជាច្រើនដែលជនជាតិចាមមិនត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ដោយសារតែភាពយោគយល់ពិសេសរបស់កម្មាភិបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ៣២៤៧។

**មូលដ្ឋាន 274.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា បក្សកុម្មុយនិស្តកម្ពុជា បានដាក់ការរិតត្បិតនៅទូទាំងប្រទេសលើវប្បធម៌ចាម។ សូមមើលកថាខណ្ឌ ៣២៤៦-៥០។

**មូលដ្ឋាន 275.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើមូលហេតុសាសនា ត្រូវបានកើតឡើងទៅលើជនជាតិចាមនៅទូទាំងប្រទេសកម្ពុជា។ សូមមើលកថាខណ្ឌ ៣៣២៧-៣២។

**មូលដ្ឋាន 276.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាការបះបោរឆ្នាំ ១៩៧៥ នៅកោះផល និង ស្វាយឃ្លាំង គ្រាន់តែជាប្រតិកម្មតបទៅនឹងការរឹតត្បិតលើវប្បធម៌ចាមប៉ុណ្ណោះ។ សូមមើលកថាខណ្ឌ ៣២៥៦, ៣២៥៩។

**មូលដ្ឋាន 277.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ជនជាតិចាមជាក្រុមនយោបាយ ហើយដែលបក្សកុម្មុយនិស្តកម្ពុជា បានបញ្ជូនចាមពីភូមិភាគបូព៌ាទៅទីតាំងដទៃទៀតដោយសារតែការបះបោរឆ្នាំ ១៩៧៥ នៅកោះផល និង ស្វាយឃ្លាំង។ សូមមើលកថាខណ្ឌ ៣២១២, ៣២៥៩, ៣២៦២, ៣២៦៨, ៣៣២២, ៣៣២៣។

**មូលដ្ឋាន 278.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថាចលនានៃការផ្លាស់ប្តូរទីលំនៅរបស់ជនជាតិចាមនៅភូមិភាគបូព៌ាគឺខុសច្បាប់។ សូមមើលកថាខណ្ឌ ៣៣៣៦-៣៧។

**មូលដ្ឋាន 279.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញលើមូលហេតុនយោបាយត្រូវបានកើតឡើងទាក់ទងនឹងការបណ្តេញប្រជាពលរដ្ឋចាមពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្តាល (ឧត្តរចាស់) នៅបន្ទាប់ពីការបះបោរនៅកោះផល និង ស្វាយឃ្លាំងនៅឆ្នាំ ១៩៧៥។ សូមមើលកថាខណ្ឌ ៣៣២០-២៦។

**មូលដ្ឋាន 280.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ថា ជាការបង្ខំឱ្យផ្លាស់ប្តូ

រទីលំនៅ ត្រូវបានកើតឡើងទាក់ទងទៅនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនចាមក្នុងអំឡុងពេលជម្លៀសនៅដំណាក់កាលទីពីរ។ សូមមើលកថាខណ្ឌ ៣៣៣៥-៤០។

**មូលដ្ឋាន 281.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃភាពជឿជាក់ និង ភាពគួរឲ្យជឿជាក់បានរបស់ សាយ ដឿន, ហ៊ីម ម៉ាន, សេន ស្រ៊ុន, សំរិត មុយ, មុយ វ៉ាន់នី និង សេង ឃុយ ទាក់ទងទៅនឹងការចាប់ខ្លួននិងការសម្លាប់ចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួន។ សូមមើលកថាខណ្ឌ ៣២៩១-៩៩។

**មូលដ្ឋាន 282.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញបញ្ជាឲ្យ "បោសសម្អាត" ជនជាតិចាមនៅភូមិភាគកណ្តាល (ឧត្តរចាស់) បានចេញមកពីថ្នាក់លើ ហើយត្រូវបានអនុវត្តដោយលេខាស្រុក។ សូមមើលកថាខណ្ឌ ៣២៩០។

**មូលដ្ឋាន 283.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មានជនជាតិចាមមួយចំនួនធំដែលមកពីភូមិនានានៃស្រុកកងមាសត្រូវបានចាប់ខ្លួនជាប្រព័ន្ធ និង បាននាំយកទៅមន្ទីរសន្តិសុខវត្តអូរត្រកួននៅឆ្នាំ ១៩៧៧ ហើយត្រូវបានសម្លាប់ជាច្រើន។ សូមមើលកថាខណ្ឌ ៣៣០២, ៣៣០៤។

**មូលដ្ឋាន 284.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពជឿជាក់ និង ភាពគួរឲ្យជឿជាក់បាននៃភស្តុតាងរបស់ អ៊ិត សេន, នោ សាតាស និង ម៉ាត់ ស ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខភូមិទ្រានៅឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ៣២៨០។

**មូលដ្ឋាន 285.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញការបញ្ជាឲ្យ "បោសសំអាត" ចាមនៅភូមិភាគបូព៌ាគឺបានចេញមកពី "ថ្នាក់លើ" រួមទាំងមកពី កែ ពក។ សូមមើលកថាខណ្ឌ ៣២៧៥។

**មូលដ្ឋាន 286.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថានៅឆ្នាំ ១៩៧៨ មានបុគ្គលមួយចំនួនត្រូវបានគេនាំទៅមន្ទីរសន្តិសុខភូមិទ្រា ជាកន្លែងដែលត្រូវបានកំណត់ថា ចាមត្រូវបានសម្លាប់នៅទៅនោះ។ សូមមើលកថាខណ្ឌ ៣២៨១។

**មូលដ្ឋាន 287.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់ និង ការសម្លាប់រង្គាលត្រូវបានកើតឡើងទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួននៅក្នុងឆ្នាំ ១៩៧៧ និង មន្ទីរសន្តិសុខភូមិទ្រានៅឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ៣៣០៦-០៨, ៣៣១០-១៣។

**មូលដ្ឋាន 288.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញថា ការវាយដំដោយខុសច្បាប់ ជាអំពើធ្វើទារុណកម្មដែលបណ្តាលឱ្យឈឺចាប់ ឬមានការឈឺចាប់ធ្ងន់ធ្ងរ។ សូមមើលកថាខណ្ឌ ៣៣១៨។

**មូលដ្ឋាន 289.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាអ្នកទោស អ៊ិត សេន និង អ្នកជាប់ឃុំជាមួយដែលជាជនជាតិចាមត្រូវបានគេវាយដំម្តងហើយម្តងទៀតនៅមន្ទីរសន្តិសុខភូមិទ្រា។ សូមមើលកថាខណ្ឌ ៣២៧៦, ៣៣១៧-១៨។

**មូលដ្ឋាន 290.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្មត្រូវបានកើតឡើងទាក់ទងនឹងការវាយដំ និង ការសួរចម្លើយជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រានៅថ្ងៃចាប់ខ្លួន អ៊ិត សេន នៅឆ្នាំ ១៩៧៨ ។ សូមមើលកថាខណ្ឌ ៣៣១៧-១៩។

**មូលដ្ឋាន 291.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អវត្តមាននៃនីតិវិធីត្រឹមត្រូវ បានធ្វើឱ្យមានការឃុំឃាំងជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រា។ សូមមើលកថាខណ្ឌ ៣៣១៥។

**មូលដ្ឋាន 292.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ពន្ធនាគារត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខភូមិទ្រា ទាក់ទងទៅនឹងអ្នកទោសជនជាតិចាម។ សូមមើលកថាខណ្ឌ ៣៣១៤-១៦។

**មូលដ្ឋាន 293.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ជនដែលដល់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន និង ភូមិទ្រា មានចេតនាប្រល័យពូជសាសន៍ចំពោះជនជាតិចាម ដែលត្រូវបានសម្លាប់នៅទីនោះ។ សូមមើលកថាខណ្ឌ ៣៣៤៥-៤៧។

**មូលដ្ឋាន 294.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការសម្លាប់ ត្រូវបានកើតឡើងទៅលើជនជាតិចាម។ សូមមើលកថាខណ្ឌ ៣៣៤៣-៤៨។

## XVIII. ការប្រព្រឹត្តលើជនជាតិវៀតណាម

មូលដ្ឋានខាងក្រោមនេះជាកំហុសដែលនឹងធ្វើឲ្យមោឃរាល់ការផ្តន្ទាទោសទាំងអស់ដែលទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាម លើកលែងតែនៅមន្ទីរសន្តិសុខស-២១:

**មូលដ្ឋាន 295.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមនៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយ:

(a) ក្នុងការរកឃើញថាទូកវៀតណាមចូលដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាប់ ឬដាក់គោលដៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ហើយថាអ្នកនេសាទវៀតណាម និង ជនភៀសខ្លួនមួយចំនួនត្រូវបានសម្លាប់។ សូមមើលកថាខណ្ឌ ៣៤៥៩-៦១; E៣៨០/២។

(b) ក្នុងការរកឃើញថាប្រជាជនវៀតណាមនិងខ្មែរក្រោមត្រូវបានប្រមូលផ្តុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលកថាខណ្ឌ ៨១៦, ២៨០៦។

**មូលដ្ឋាន 296.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថាពាក្យ "យួន" ត្រូវបានគេប្រើក្នុងលក្ខណៈប្រមាថមើលងាយហើយរួមបញ្ចូលជនស៊ីវិល យុទ្ធជន ឬក៏អាស្រ័យលើបរិបទ។ សូមមើលកថាខណ្ឌ ៣៣៨១។

**មូលដ្ឋាន 297.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ដោយពឹងផ្អែកលើភ័ស្តុតាងរបស់ ឯក ហឿន ទាក់ទងនឹងការប្រព្រឹត្តលើប្រជាជនវៀតណាមនៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១១១១-១២, ១១២១-២២។

**មូលដ្ឋាន 298.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញថា ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលដាក់គោលដៅលើជនជាតិវៀតណាមដោយការប្រព្រឹត្តមិនល្អ:

(a) ក្នុងការរកឃើញថា ការយល់ព្រមរបស់វៀតណាមខាងជើងចំពោះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានពន្យល់មួយផ្នែកពីការកំណត់អត្តសញ្ញាណរបស់ជនជាតិវៀតណាមនៅកម្ពុជាដែលជាក្រុមមួយដែលសមនឹងទទួលបានការយកចិត្តទុកដាក់ខុសគ្នា។ សូមមើលកថាខណ្ឌ ៣៣៨២។

(b) ក្នុងការរកឃើញគោលនយោបាយ "មួយទល់នឹង ៣០" របស់ ប៉ុល ពត ត្រូវបានសំដៅដោយផ្ទាល់ប្រឆាំងនឹងប្រជាជនវៀតណាម។ សូមមើលកថាខណ្ឌ ៣៤០២។

(c) ក្នុងការរឃើញថា ការចាក់ផ្សាយដែលបានធ្វើនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ ដោយអ្នកផ្សព្វផ្សាយវិទ្យុមិនស្គាល់អត្តសញ្ញាណនៅរាជធានីភ្នំពេញ ដែលបានអំពាវនាវឱ្យសម្លាប់ខ្មាំងបានចេញដោយមជ្ឈឹមបក្ស ហើយដាក់គោលដៅទាំងទាហានវៀតណាម និង ជនស៊ីវិល។ សូមមើលកថាខណ្ឌ ៣៣៩៨។

(d) ក្នុងការរកឃើញថា សុន្ទរកថាដែលធ្វើឡើងដោយ ខៀវ សំផន នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ បានសំដៅទៅលើប្រជាជនវៀតណាមទាំងអស់ដោយមិនរើសមុខ។ សូមមើលកថាខណ្ឌ ៣៣៩៩។

**មូលដ្ឋាន 299.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថាសុន្ទរកថាខួបលើកទី១ ក្នុងឆ្នាំ ១៩៧៦ បានឆ្លុះបញ្ចាំងពីការស្អប់របស់បក្សកុម្មុយនិស្តកម្ពុជា ចំពោះជនបរទេស និង ជាពិសេសជនជាតិវៀតណាម។ សូមមើលកថាខណ្ឌ ៣៣៨៧-៨៨។

**មូលដ្ឋាន 300.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឯកសារដែលបានដកស្រង់ដោយមេធាវីការពារក្តី ដែលបានស្នើសុំឱ្យមានមិត្តភាពជាមួយវៀតណាម មិនបង្ហាញឲ្យលើសពីវិមតិសង្ស័យ ចំពោះការកំណត់គោលដៅរបស់ប្រជាជនវៀតណាមនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យនោះទេ។ សូមមើលកថាខណ្ឌ ៣៤០៤។

**មូលដ្ឋាន 301.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា "បក្សកុម្មុយនិស្តកម្ពុជា" ចាត់ទុកថា ជាតិសាសន៍វៀតណាម ដែលត្រូវបានរៀបអាពាហ៍ពិពាហ៍ ហើយជាលទ្ធផលបានដាក់គោលដៅលើគ្រួសារដែលម្តាយជាវៀតណាម។ សូមមើលកថាខណ្ឌ ៣៤២៨។

**មូលដ្ឋាន 302.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ត្រូវបានដាក់ជាគោលដៅ ដោយផ្អែកលើជាតិសាសន៍របស់ពួកគេ ហើយថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជា បានដាក់ចេញជាច្រើនដងនៃការណែនាំឲ្យសម្លាប់ប្រជាជនវៀតណាម។ សូមមើលកថាខណ្ឌ ១១២៥។

**មូលដ្ឋាន 303.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែងទាក់ទងនឹងការសម្លាប់ប្រជាជនវៀតណាម៦នាក់។ សូមមើលកថាខណ្ឌ ២៩២៦, ២៩៥៩។

**មូលដ្ឋាន 304.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកើតឡើងទាក់ទងនឹងការសម្លាប់ជនស៊ីវិលវៀតណាមនៅខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨ នៅដែនទឹកកម្ពុជាក្រោយខែមេសាឬ ឧសភា ឆ្នាំ ១៩៧៧ និង នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ នៅខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ ១៩៧៧។ នៅវត្តខ្សាច់ នៅចុងឆ្នាំ ១៩៧៨។ និងខេត្តក្រចេះនៅខែកញ្ញា ឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ៣៤៥៣-៥៥, ៣៤៥៩-៦១, ៣៤៨២, ៣៤៨៨, ៣៤៩១-៩៧។

**មូលដ្ឋាន 305.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលត្រូវបានកើតឡើងទាក់ទងនឹងការសម្លាប់ជនស៊ីវិលវៀតណាមនៅខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨ នៅដែនទឹកកម្ពុជាក្រោយខែមេសាឬ ឧសភា ឆ្នាំ ១៩៧៧ និង នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ នៅខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ ១៩៧៧។ នៅវត្តខ្សាច់ នៅចុងឆ្នាំ ១៩៧៨ និងនៅខេត្តក្រចេះ ខែ កញ្ញា ឆ្នាំ ១៩៧៨។ សូមមើលកថាខណ្ឌ ៣៤៩៩-៥០១។

**មូលដ្ឋាន 306.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ចំនួនប្រជាជនវៀតណាមភាគច្រើនត្រូវបានប្រមូលផ្ដុំនៅស្រុកត្រាំកក់ និងត្រូវបានបណ្ដេញចេញ ឬ បាត់ខ្លួន។ សូមមើលកថាខណ្ឌ ១១២៥។

**មូលដ្ឋាន 307.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថារបៀបដែលប្រជាជនវៀតណាមនៅស្រុកត្រាំកក់ត្រូវបានប្រមូលផ្តុំ បង្ហាញថាពួកគេមានវត្តមានស្របច្បាប់នៅក្នុងតំបន់នោះនៅពេលនោះ។ សូមមើលកថាខណ្ឌ ១១៥៧។

**មូលដ្ឋាន 308.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃកាផ្លាស់ប្តូរទីកន្លែង ត្រូវបានកើតឡើងនៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១១៥៦-៥៩។

**មូលដ្ឋាន 309.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ប្រជាជនវៀតណាមមួយចំនួនធំនៅក្នុងខេត្តព្រៃវែងត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីលំនៅពីកម្ពុជាទៅវៀតណាម។ សូមមើលកថាខណ្ឌ ៣៤៣៣-៣៦។

**មូលដ្ឋាន 310.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេសត្រូវបានកើតឡើងទាក់ទងទៅនឹងប្រជាជនវៀតណាមដែលត្រូវបានបណ្តេញចេញពីខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៦។ សូមមើលកថាខណ្ឌ ៣៥០៣-០៧។

**មូលដ្ឋាន 311.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញទៅលើពូជសាសន៍ត្រូវបានកើតឡើងនៅសហករណ៍ត្រាំកក់ទាក់ទងនឹងជនជាតិវៀតណាម។ សូមមើលកថាខណ្ឌ ១១៨៨-៩២។

**មូលដ្ឋាន 312.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើពូជសាសន៍ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែងទាក់ទងទៅនឹងការសម្លាប់ប្រជាជនវៀតណាម ៦នាក់។ សូមមើលកថាខណ្ឌ ២៩៩៦-៩៩។

**មូលដ្ឋាន 313.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើពូជសាសន៍ត្រូវបានកើតឡើងទាក់ទងនឹងវៀតណាមនៅខេត្ត ព្រៃវែង និង ស្វាយរៀង។ សូមមើលកថាខណ្ឌ ៣៥០៩-១៣។

**មូលដ្ឋាន** 314. អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃការសម្លាប់សមាជិកនៃក្រុមវៀតណាមត្រូវបាន កើតឡើង។ សូមមើលកថាខណ្ឌ ៣៥១៥-១៩។

## XIX. ការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ

មូលដ្ឋានខាងក្រោមនេះជាកំហុស ដែលនឹងធ្វើឱ្យមោឃរាល់ការផ្តន្ទាទោសទាក់ទងនឹងការប្រព្រឹត្តលើអតីត មន្ត្រីសាធារណរដ្ឋខ្មែរ:

**មូលដ្ឋាន** 315. អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការបដិសេធថាសិទ្ធិរបស់ នួន ជា ត្រូវបានជូនដំណឹងទាន់ពេល និង លម្អិតអំពីលក្ខណៈ និង មូលហេតុនៃការចោទប្រកាន់ប្រឆាំងរូប គាត់ មិនត្រូវបានរំលោភបំពាន ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា នៃការដាក់ គោលដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ១៧១-៧៦, ១៤៣៦-៣៧, ២៤៨៥, ២៦៤៣។

**មូលដ្ឋាន** 316. អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការអនុវត្តបទដ្ឋានពីរ ចំពោះការវាយតម្លៃភស្តុ តាងដែលពឹងផ្អែកដោយមេធាវីការពារក្តី ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់ក្នុងការកំណត់គោលដៅទៅលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ។ សូមមើលកថា ខណ្ឌ ៤០៣០-៣១, ៤០៣៥, ៤០៣៧, ៤០៤០។

**មូលដ្ឋាន** 317. អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការពឹងផ្អែកយ៉ាងច្រើនទៅលើភ័ស្តុតាងរបស់ Philip Short ដែលការសន្និដ្ឋានរបស់គាត់ទាក់ទងទៅនឹងការចោទប្រកាន់លើអតីតមន្ត្រី សាធារណរដ្ឋខ្មែរត្រូវបានយោងលើប្រភពមិនច្បាស់លាស់និងមិនទាន់បានដេញដោល។ សូមមើលកថា ខណ្ឌ ៤០៤៥។

**មូលដ្ឋាន** 318. អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ ក្នុងការខកខានមិនបានពិចារណាឱ្យបានគ្រប់គ្រាន់ លើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា

ដែលត្រូវបានចោទប្រកាន់ក្នុងការដាក់គោលដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ១០៦៣, ៤០២៥។

**មូលដ្ឋាន 319.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា គោលនយោបាយទូទាំងប្រទេស ដែលកំណត់គោលដៅលើមន្ត្រីអតីតរបបសាធារណរដ្ឋខ្មែរ កើតមានភ្លាមៗបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញ ហើយនៅទូទាំងឆ្នាំ ១៩៧៥។ សូមមើលកថាខណ្ឌ ៤០៤១, ៤០៤៧។

**មូលដ្ឋាន 320.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា មិនប៉ះពាល់ដល់អតីតមន្ត្រីសាធារណរដ្ឋខ្មែរបានផ្លាស់ប្តូរនៅឆ្នាំ ១៩៧៦។ សូមមើលកថាខណ្ឌ ១០៦៣។

**មូលដ្ឋាន 321.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មានគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា យ៉ាងទូលំទូលាយដែលផ្តោតលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ដោយប្រព្រឹត្តមិនល្អទៅលើពួកគេនៅអំឡុងពេល "កម្ពុជាប្រជាធិបតេយ្យ"។ សូមមើលកថាខណ្ឌ ៤០៤៩។

**មូលដ្ឋាន 322.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោម ទាក់ទងនឹងការប្រព្រឹត្តដោយរើសអើងចំពោះអតីតមន្ត្រីសាធារណរដ្ឋខ្មែរ:

(a) ថា ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងសមាជិកគ្រួសារនៃអតីតរបបនេះត្រូវបានហាត់ធ្វើការ ឬ បង្ខំឱ្យធ្វើការងារនៅមន្ទីរសន្តិសុខ។ សូមមើលកថាខណ្ឌ ៤០៤៧។

(b) ថា មានការកំណត់អត្តសញ្ញាណមន្ត្រីសាធារណរដ្ឋខ្មែរ និង ទាហានដែលមានឋានៈខ្ពស់តាមរយៈការរៀបចំបញ្ជីនៅថ្នាក់ស្រុក និង តំបន់ដើម្បីចាប់ខ្លួនពួកគេ។ សូមមើលកថាខណ្ឌ ១៦៩០-៩២។

**មូលដ្ឋាន 323.** អង្គជំនុំជម្រះមានកំហុសលើអង្គហេតុ ក្នុងការរកឃើញថា មានផែនការសម្លាប់អតីតមន្ត្រី និង ទាហានសាធារណរដ្ឋខ្មែរនៅស្រុកត្រាំកក់។ សូមមើលកថាខណ្ឌ ៩៦៤-៦៥។

**មូលដ្ឋាន 324.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ ត្រូវបានចាប់ខ្លួន សម្លាប់ ឬ ក៏បាត់ខ្លួននៅសហករណ៍ត្រាំកក់។ សូមមើលកថាខណ្ឌ ១០៧០-៨៣, ១២០០-០៤។

**មូលដ្ឋាន 325.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ដែលថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានកើតឡើងនៅសហករណ៍ត្រាំកក់ប្រឆាំងនឹងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ១១៧៣-៧៥, ១១៧៧-៧៩។

**មូលដ្ឋាន 326.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អំពើអមនុស្សធម៌ផ្សេងទៀតប្រព្រឹត្តតាមរយៈការបាត់ខ្លួនដោយបង្ខំ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅសហករណ៍ត្រាំកក់ទាក់ទងនឹងអតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ។ សូមមើល កថាខណ្ឌ ១២០១-០៤។

**មូលដ្ឋាន 327.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ដោយពឹងផ្អែកលើព្រឹត្តការណ៍ដែលស្ថិតនៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយ ដើម្បីសម្រេចអំពីការប្រព្រឹត្តលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៦៦០-៦២។

**មូលដ្ឋាន 328.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា មានអ្នកខ្លះត្រូវបានគេកំណត់គោលដៅដើម្បីចាប់ខ្លួន និង បានបាត់ខ្លួនដោយសារតែទំនាក់ទំនងរបស់ពួកគេជាមួយមន្ត្រីរបបសាធារណរដ្ឋខ្មែរ នៅការដ្ឋានការងារទំនប់ ១ មករា។ សូមមើលកថាខណ្ឌ ១៦៦៣។

**មូលដ្ឋាន 329.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើមូលដ្ឋាននយោបាយត្រូវបានកើតឡើងនៅការដ្ឋានសាងសង់ទំនប់ ១ មករាប្រឆាំងនឹងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ១៦៩០-៩២។

**មូលដ្ឋាន 330.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា អតីតមន្ត្រីសាធារណរដ្ឋខ្មែរក៏ដូចជាសាច់ញាតិរបស់ពួកគេត្រូវបានគេកំណត់គោលដៅសម្រាប់ការចាប់ខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខស-២១។ សូមមើលកថាខណ្ឌ ២៤៩២។

**មូលដ្ឋាន 331.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ទាក់ទងនឹងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ២៥៩៩-៦០៥។

**មូលដ្ឋាន 332.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ទាក់ទងទៅនឹងការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ២៨១៣។

**មូលដ្ឋាន 333.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ទាក់ទងនឹងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមមើលកថាខណ្ឌ ២៨៣៨-៤៣។

## XX. បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍

មូលដ្ឋានខាងក្រោមនេះគឺជាកំហុស ដែលនឹងនាំឱ្យមោឃចំពោះការផ្តន្ទាទោសទាំងអស់ដែលទាក់ទងនឹងបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍:

**មូលដ្ឋាន 334.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា ការផ្តន្ទាទោស នួន ជា ចំពោះអំពើអមនុស្សធម៌ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺពុំបានរំលោភលើគោលការណ៍ច្បាប់ និងថា ការធ្វើរបៀបនេះគឺស្រដៀងគ្នានឹងភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែរ។ សូមមើលកថាខណ្ឌ ៧៤១, ៧៤៣-៤៩, ៣៦៨៨, ៣៦៩១-៩២។

**មូលដ្ឋាន 335.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងការអនុវត្តបទដ្ឋានពីរ ចំពោះការវាយតម្លៃភស្តុតាងរបស់អ្នកជំនាញស្តីពីបទបញ្ញារៀបអាពាហ៍ពិពាហ៍។ សូមមើលកថាខណ្ឌ ៣៥២៩-៣៤។

**មូលដ្ឋាន 336.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការវាយតម្លៃភស្តុតាងនៃការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំសម្រាប់គោលបំណងនៃការយល់

ដឹងអំពីបរិបទទូទៅក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានគេអនុវត្ត ដោយរួមទាំងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា សម្រាប់ការរំលោភសេពសន្ថវៈជាទូទៅ។ សូមមើលកថាខណ្ឌ ៣៥៣៥។

**មូលដ្ឋាន 337.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញនូវភាពជឿជាក់ និង ភាពគួរឲ្យជឿទុកចិត្តបាននៃភ័ស្តុតាងដោះបន្ទុក ដែលបានមកពីកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជា ពាក់ព័ន្ធនឹងបទបញ្ជារៀបអាពាហ៍ពិពាហ៍:

(a) ថា សក្ខីកម្មរបស់ ប្រាក់ យុត ទាក់ទងនឹងកំរិតរដ្ឋបាល ដែលការរៀបអាពាហ៍ពីពាហ៍ត្រូវបានអនុញ្ញាតនោះ គឺមិនគួរឱ្យទុកចិត្តបានទេ។ សូមមើលកថាខណ្ឌ ៣៦០៩, ៣១៩១។

(b) ការយល់ព្រមរបស់បុគ្គលសម្រាប់ការរៀបអាពាហ៍ពីពាហ៍តាមការផ្គូរផ្គងនោះ ពុំមានការយល់ព្រមពិតប្រាកដឡើយ ហើយកម្មាភិបាលដែលបានផ្តល់ភស្តុតាងដូចនេះ គឺមានទំនោចង់កាត់បន្ថយការទទួលខុសត្រូវរបស់ខ្លួនតែប៉ុណ្ណោះ។ សូមមើលកថាខណ្ឌ ៣៦២៣, ៣៦២៥, ៣៦៧៥។

(c) ថាក្រៅពីការលើកឡើងរបស់ សេង អុល ថាការរៀបអាពាហ៍ពិពាហ៍នៅក្នុងកងរបស់គាត់ពុំត្រូវបានបង្ខំឡើយ ហើយការរៀបការកើតឡើងដោយការព្រមព្រៀងរវាងបុគ្គលម្នាក់ៗ ដែលថាការ "ព្រមព្រៀង" ដោយពុំមានការភ័យខ្លាច។ សូមមើលកថាខណ្ឌ ៣៦៧៣។

**មូលដ្ឋាន 338.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ និង បំពានលើឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការវាយតម្លៃរបស់ខ្លួនលើភាពគួរឱ្យជឿជាក់បាន និងភាពគួរឱ្យទុកចិត្តបាននៃដើមបណ្តឹងរដ្ឋប្បវេណី អ៊ំ យឿន, មុំ វ៉ុន និង ព្រាប សុខឿន។ សូមមើលកថាខណ្ឌ ៣៦៤៩។

**មូលដ្ឋាន 339.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ដើម្បីគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍:

(a) ថាបក្សកុម្មុយនិស្តកម្ពុជាបានឃើញគ្រួសារ និង អាពាហ៍ពិពាហ៍ មានសារៈសំខាន់ណាស់ក្នុងការកសាងសង្គមថ្មីមួយ ដែលស្របតាមមនោគមវិជ្ជានៃបដិវត្តន៍សង្គមនិយមរបស់ខ្លួន ហើយស្របតាមទស្សនៈគ្រួសារនិងអាពាហ៍ពិពាហ៍ពីទស្សនវិស័យសមូហភាព បញ្ជាក់ពីការចាកចេញផុតពីប្រពៃណីខ្មែរ។ សូមមើលកថាខណ្ឌ ៣៥៣៩។

(b) ថាបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកកុមារថា ជាធនធានដ៏ល្អបំផុតសម្រាប់បដិវត្តន៍ហើយថា "អង្គការ" ត្រូវបានដាក់ខ្ពស់ជាងឪពុកម្តាយ ឬក៏មានបំណងជំនួសឪពុកម្តាយ។ សូមមើលកថាខណ្ឌ ៣៥៣៩។

(c) ថា "អង្គការ" តែមួយគត់អាចធ្វើការវាយតម្លៃលើបញ្ហាកសាងគ្រួសារ។ សូមមើលកថាខណ្ឌ ៣៥៤១។

(d) ថាការព្រមព្រៀងនៃសាមីខ្លួនរៀបអាពាហ៍ពិពាហ៍ពុំសូវមានសារៈសំខាន់ជាងការយល់ព្រមចំពោះការណែនាំរបស់ "អង្គការ"។ សូមមើលកថាខណ្ឌ ៣៥៤៨។

(e) ថា គោលបំណងនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺដើម្បីបង្កើនចំនួនប្រជាជន និងមួយផ្នែកទៀតគឺបង្កើនចំនួនទាហាន។ សូមមើលកថាខណ្ឌ ៣៥៤៧-៥៨។

**មូលដ្ឋាន 340.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងបទបញ្ញាលើទំនាក់ទំនាក់ក្រៅអាពាហ៍ពិពាហ៍:

(a) ថាគោលបំណងនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ស្តីពីការរៀបអាពាហ៍ពិពាហ៍គឺដើម្បីគ្រប់គ្រងទំនាក់ទំនង មនោសញ្ចេតនា ឬផ្លូវភេទរវាងបុរសនិងស្ត្រីនៅក្រៅអាពាហ៍ពិពាហ៍។ សូមមើលកថាខណ្ឌ ៣៥៥៩។

(b) ថាការហាមឃាត់របស់បក្សកុម្មុយនិស្តកម្ពុជា លើអាកប្បកិរិយារំលោភបំពានលើស្ត្រីដូចមានចែងនៅក្នុងប្រការទី ៦ ពាក់ព័ន្ធនឹងទំនាក់ទំនងដែលនៅក្រៅចំណងអាពាហ៍ពិពាហ៍ ជាជាងទង្វើមិនស្ម័គ្រចិត្តដែលប្រព្រឹត្តចំពោះស្ត្រីជាទូទៅ។ សូមមើលកថាខណ្ឌ ៣៥៦០។

(c) ថាការទំនាក់ទំនង និងក្នុងករណីខ្លះទំនាក់ទំនងជាទូទៅរវាងបុរស និងស្ត្រីនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាជាកំហុសខាងសីលធម៌។ សូមមើលកថាខណ្ឌ ៣៥៦៣។

**មូលដ្ឋាន 341.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការវាយតម្លៃលើអំណះអំណាងក្រុមមេធាវីការពារក្តី ពីភាពស្រដៀងគ្នាចំពោះការរៀបអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ និងបទបញ្ញារៀបអាពាហ៍ពិពាហ៍នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ សូមមើលកថាខណ្ឌ ៣៦៨៨-៩០។

**មូលដ្ឋាន 342.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញដូចខាងក្រោមទាក់ទងនឹងរចនាសម្ព័ន្ធត្រួតពិនិត្យ និង រាយការណ៍ទាក់ទងនឹងបទបញ្ញារៀបអាពាហ៍ពិពាហ៍:

(a) ថា ការណែនាំទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ត្រូវបានទាក់ទងពី "ថ្នាក់លើ"។ សូមមើលកថាខណ្ឌ ៣៥៦៥-៦៦។

(b) ថា ខៀវ សំផន បានផ្តល់ការណែនាំដោយផ្ទាល់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ និងការកសាងគ្រួសារ។ សូមមើលកថាខណ្ឌ ៣៥៦៩, ៣៥៧១។

(c) ថាគ្រប់ក្រសួងទាំងអស់នៃរដ្ឋាភិបាលរបបកម្ពុជាប្រជាធិប្បតេយ្យត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍។ សូមមើលកថាខណ្ឌ ៣៥៧០។

**មូលដ្ឋាន 343.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការផ្គូរផ្គងដើម្បីរៀបអាពាហ៍ពិពាហ៍:

(a) ថាប្រជាជនដែលមានសាវតាដូចគ្នាត្រូវបានផ្គូរផ្គងឱ្យរៀបការជាមួយគ្នា ហើយមានតែក្នុងករណីកម្រខ្លះប៉ុណ្ណោះដែលប្រជាជនដែលមានសាវតាខុសប្លែកគ្នាត្រូវអនុញ្ញាតអោយរៀបការនឹងគ្នា។ សូមមើលកថាខណ្ឌ ៣៥៧៨, ៣៥៨០។

(b) ថាជនជាតិចាម ត្រូវផ្គូផ្គងឱ្យរៀបការជាមួយជនជាតិចាមផ្សេងទៀត ហើយថា ការរៀបការដែលខុសជាតិសាសន៍គ្នា មិនត្រូវបានអនុញ្ញាតិឡើយ។ សូមមើលកថាខណ្ឌ ៣៥៧៩។

(c) ថាអាយុរបស់នារីដែលអាចរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីអាយុ១៦ទៅ៦០ឆ្នាំ។ សូមមើលកថាខណ្ឌ ៣៥៨៣។

(d) ថានារីដែលត្រូវរៀបការជាមួយទាហានពិកា ត្រូវតែរំពឹងថា ត្រូវធ្វើដូច្នេះ ដើម្បីផលប្រយោជន៍របស់បដិវត្តន៍។ សូមមើលកថាខណ្ឌ ៣៥៩០។

**មូលដ្ឋាន 344.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងនឹងការយល់ព្រមរៀបអាពាហ៍ពិពាហ៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យ:

(a) ថាដោយសារតែបរិយាកាសភ័យខ្លាច ប្រជាជនពុំមានជម្រើសផ្សេងក្រៅពីការរៀបការតាមការណែនាំរបស់បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ៣៦៧៤, ៣៦៧៦, ៣៦៧៨។

(b) ប្រជាជនមិនអាចបដិសេធការរៀបការ ដោយគ្មានលទ្ធផលឈឺចាប់នោះទេ។ សូមមើលកថាខណ្ឌ ៣៦២៥។

(c) ថាខណៈដែលកម្មាភិបាលជាបុរសនៃបក្សកុម្មុយនិស្តកម្ពុជាខ្លះត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រពន្ធរបស់ខ្លួន ប៉ុន្តែប្រពន្ធរបស់ពួកគេត្រូវបានបង្ខំឱ្យរៀបការដោយមិនបានសួរជាមុន។ សូមមើលកថាខណ្ឌ ៣៥៩១។

(d) ថាកម្មាភិបាលថ្នាក់ក្រោមនៃបក្សកុម្មុយនិស្តកម្ពុជាបានផ្គូផ្គងឱ្យប្រជាជនរៀបអាពាហ៍ពិពាហ៍ ហើយបន្ទាប់មកបានស្នើបញ្ជីឈ្មោះទាំងនេះទៅកម្មាភិបាលថ្នាក់លើដើម្បីសម្រេចតាមសំណើ។ សូមមើលកថាខណ្ឌ ៣៥៩៨។

(e) ថា ខណៈដែលភស្តុតាងខ្លះបាននាំឱ្យចេញសេចក្តីសម្រេចលើការរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើដោយកម្មាភិបាលថ្នាក់ក្រោម ប៉ុន្តែជាទូទៅការសម្រេចបានមកពី "ថ្នាក់លើ"។ សូមមើលកថាខណ្ឌ ៣៦០៨។

(f) ថាក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ "អង្គការ" បានជំនួសតួនាទីរបស់ឪពុកម្តាយ ហើយឪពុកម្តាយមិនត្រូវបានពាក់ព័ន្ធនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយការផ្គូផ្គងសម្រាប់កូនៗរបស់ខ្លួន។ សូមមើលកថាខណ្ឌ ៣៦១៣។

(g) ថា ចំពោះការបដិសេធនូវភស្តុតាងផ្ទុយទាំងអស់ បក្សកុម្មុយនិស្តកម្ពុជា តម្រូវឱ្យសមាជិកបក្ស កម្មាភិបាល យុទ្ធជន និងប្រជាជនទូទៅ ត្រូវតែគោរពដោយឥតលក្ខខណ្ឌនូវវិន័យបក្ស មាគ៌ាបក្ស ឬក៏អ្វីដែល "អង្គការ" បានបញ្ជា រួមទាំងការរៀបអាពាហ៍ពិពាហ៍។ សូមមើលកថាខណ្ឌ ៣៦១៨-១៩, ៣៦២៣, ៣៦២៥។

**មូលដ្ឋាន 345.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា ប្រជាជនដែលត្រូវបានផ្គូផ្គងដើម្បីរៀបការជាមួយគ្នា ពុំត្រូវបានសួរយោបល់ និងពុំមានការជូនដំណឹងបន្តិចសោះថាពួកគេត្រូវរៀបការ។ សូមមើលកថាខណ្ឌ ៣៦១៦។

**មូលដ្ឋាន 346.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ ក្នុងការរកឃើញថា ពិធីអាពាហ៍ពិពាហ៍ធ្វើឡើងនៅរបបកម្ពុជាប្រជាធិបតេយ្យ ពុំបានប្រារព្ធតាមប្រពៃណីខ្មែរឡើយ។ សូមមើលកថាខណ្ឌ ៣៦៣៨។

**មូលដ្ឋាន 347.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុក្នុងការរកឃើញខាងក្រោមទាក់ទងទៅនឹងការរួមភេទក្រោយការរៀបអាពាហ៍ពិពាហ៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យ:

(a) ថាបន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ ស្វាមីភរិយា ជាទូទៅត្រូវគេតាមដាន ដើម្បីធានាថាពួកគេបានរួមដំណេកតាមការរៀបការរបស់ខ្លួន។ សូមមើលកថាខណ្ឌ ៣៦៤៤, ៣៦៥៩-៦១។

(b) ថាការរំលោភ ត្រូវបានប្រើប្រាស់ដើម្បីដាក់ទណ្ឌកម្មដល់ប្រជាជនដែលបដិសេធមិនព្រមរួមដំណេកតាមការរៀបការរបស់ខ្លួន។ សូមមើលកថាខណ្ឌ ៣៦៥៨។

**មូលដ្ឋាន 348.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា បក្សកុម្មុយនិស្តកម្ពុជា ពុំអនុញ្ញាតឱ្យគូស្រករដែលបានរៀបការដោយ "អង្គការ" លែងលះគ្នាទេ។ សូមមើលកថាខណ្ឌ ៣៦៦៩។

**មូលដ្ឋាន 349.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា នៅតំបន់មួយចំនួននៃប្រទេស ជាជាងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ជាក់លាក់ថា ប្រជាជនពុំមានជម្រើសឡើយ ប៉ុន្តែរៀបការទៅតាមការណែនាំរបស់បក្សកុម្មុយនិស្តកម្ពុជា។ សូមមើលកថាខណ្ឌ ៣៦៧០។

**មូលដ្ឋាន 350.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា អំពើអមនុស្សធម៌ផ្សេងទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តនៅទូទាំងប្រទេស តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សូមមើលកថាខណ្ឌ ៣៦៨៧-៩៤។

**មូលដ្ឋាន 351.** អង្គជំនុំជម្រះមានកំហុសលើអង្គច្បាប់ និង អង្គហេតុ នៅក្នុងការរកឃើញថា អំពើអមនុស្សធម៌ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសតាមរយៈការរំលោភនៅក្នុងបរិបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សូមមើលកថាខណ្ឌ ៣៦៩៦-៧០០។

សហមេធាវីការពារក្តីលោក នួន ជា

សុន អរុណ លីវ សុវណ្ណា Doreen CHEN